# វគ្គទី ១
# ភូមិកំណើតខ្ញុំ
# (ទសវត្សរ៍ឆ្នាំ ១៩៥០-១៩៦០)

ខ្ញុំកើតនៅភូមិស្នាយពល ក្នុងឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង នៅឆ្នាំ ១៩៥០ គឺជាងហុកសិបឆ្នាំមកហើយ ។ ភូមិស្នាយពល ជាទីរួមស្រុកនៃស្រុកពារាំង ដែលស្ថិតនៅ ផ្នែកបូព៌ានៃប្រទេសកម្ពុជា ។ នៅពេលនោះ ភូមិនេះមានប្រជាពលរដ្ឋតែ ៥០០ ឬ ៦០០ នាក់ប៉ុណ្ណោះ ។ ភូមិស្នាយពលមានចំងាយប្រហែល ៧០ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ក៏ប៉ុន្តែដោយសារហេដ្ឋារចនាសម្ព័ន្ធខាងផ្នែកគមនាគមន៍មិនល្អ ការធ្វើដំណើរពីរាជធានីភ្នំពេញមានការលំបាកជាខ្លាំង ។

ដើម្បីបានជាប្រយោជន៍ដល់អ្នកសិក្សាជំនាន់ក្រោយ ខ្ញុំសូមបង្ហាញអំពីព្រឹត្តិការណ៍ជាតិ និង អន្តរជាតិខ្លះៗ ក្នុងបរិបទប្រវត្តិសាស្ត្រនៅសម័យនោះ ដែលមានការពាក់ព័ន្ធនឹងចំណុចនានាជាបន្តបន្ទាប់ ។

ប្រទេសកម្ពុជាជាប្រទេសមួយនៅក្នុងឧបទ្វីបឥណ្ឌូចិន ។ ឥណ្ឌូចិនជាតំបន់មួយនៅចន្លោះឥណ្ឌា និង ចិន ដែលមានប្រទេសភូមា ថៃ ឡាវ វៀតណាម និង កម្ពុជា ។ ប៉ុន្តែចាប់ពីសម័យអាណានិគមកម្មបារាំង (Colonisation française/ French colonization) នៅពាក់កណ្តាលសតវត្សទី១៩ គេសម្គាល់ឥណ្ឌូចិនចំពោះតែបីប្រទេសគឺ កម្ពុជា វៀតណាម និង ឡាវ ដែលនៅសម័យនោះ គេនិយមហៅថា ឥណ្ឌូចិនបារាំង (Indochine française)[1] ។

---

[1] French Indochina was part of the French colonial empire in Southeast Asia. ឥណ្ឌូចិនបារាំង ជាផ្នែកមួយនៃចក្រភពអាណានិគមបារាំងនៅតំបន់អាស៊ីអាគ្នេយ៍ ។

សង្គ្រាមឥណ្ឌូចិនលើកទី១ (Première Guerre d'Indochine)[2] ដែលជាសង្គ្រាមរវាងប្រទេសទាំងបីខាងលើដើម្បីទាមទារឯករាជ្យពីប្រទេសបារាំង បានចាប់ផ្តើមនៅឆ្នាំ ១៩៤៦ និង បញ្ចប់នៅឆ្នាំ ១៩៥៤ ។ សន្និសីទក្រុងហ្សឺណែវ (Conférence de Genève) ពីថ្ងៃទី ៨ ឧសភា ដល់ថ្ងៃទី ២១ កក្កដា ១៩៥៤ គឺជាសន្និសីទ ដែលប្រទេសជាច្រើនបានចូលរួម ដើម្បីបញ្ចប់សង្គ្រាមនៅឥណ្ឌូចិន ។ ប្រទេសទាំងបីនៅឥណ្ឌូចិនមានវាសនាខុសៗពីគ្នា៖ ប្រទេសវៀតណាមត្រូវបែងចែកជាពីរ ប្រទេសឡាវក៏មានរបបគ្រប់គ្រងពីរ ចំណែកប្រទេសកម្ពុជាមានឯកភាពទឹកដីទាំងស្រុងនៅឆ្នាំ ១៩៥៤ ។ លើសពីនេះទៀត យើងមានឯកភាពខាងនយោបាយចាប់ពីឆ្នាំ ១៩៥៥ នៅពេលដែលមានការបង្កើតចលនាសង្គមរាស្ត្រនិយម ។ យើងរស់នៅក្នុងសុខសន្តិភាព ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៥០ ក៏ប៉ុន្តែផ្លូវគមនាគមន៍នៅសម័យនោះ នៅមិនទាន់ល្អនៅឡើយទេ ។

## ការធ្វើដំណើរពីភូមិខ្ញុំទៅកាន់ទីក្រុង

គេច្រើនធ្វើដំណើរពីភ្នំពេញ ទៅភូមិស្វាយពល តាមទោចក្រយាន ឬ ទោចក្រយានយន្តដែលត្រូវចំណាយពេលអស់ជាងកន្លះថ្ងៃ ។ ប៉ុន្តែទោះជាមានការលំបាកយ៉ាងណាក្តី អ្នកស្រុកភូមិខ្ញុំនិយមធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញជាងធ្វើដំណើរទៅកាន់ទីរួមខេត្តព្រៃវែង ដែលមានចំងាយប្រហែលតែ ៣០ គីឡូម៉ែត្រប៉ុណ្ណោះ ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០-៧០ ផ្លូវពីស្វាយពល ទៅទីរួមខេត្ត

---

[2] The First Indochina War (December 1946- July 1954) was fought between French forces vs. Viet Minh, Pathet Lao and Khmer Issarak. សង្គ្រាមឥណ្ឌូចិនលើកទី១ ពីខែ ធ្នូ ១៩៤៦ ដល់ កក្កដា ១៩៥៤ ជាសង្គ្រាមរវាងកងកម្លាំងបារាំងប្រឆាំង ពួកវៀតមិញ ប៉ាថេតឡាវ និង ខ្មែរឥស្សរៈ ។

ព្រៃវែងនៅតែមានការលំបាកនៅឡើយ ហើយទទួលរងនូវការខូចខាតជាញឹកញាប់ដោយសារទឹកជំនន់ ។ អ្នកភូមិយើងតែងធ្វើដំណើរតាមផ្លូវថ្នល់ នៅរដូវប្រាំងដែលចាប់ផ្ដើមពីខែ វិច្ឆិកា ទៅខែ ឧសភា ។

ក្នុងសម័យនោះ មានរថយន្តឈ្នួលដឹកអ្នកដំណើរពីស្វាយពល ទៅទីរួមខេត្រព្រៃវែងចំនួនពីរគ្រឿង ។ រថយន្តមួយពណ៌ក្រហម អ្នកស្រុកច្រើនហៅថាឡានក្រហម ឬ អាក្រហម ។ រថយន្តមួយទៀតពណ៌ខៀវ គេហៅថាឡានខៀវ ឬ អាខៀវ ។ ថៅកែឡានឈ្នួលនេះជាជនជាតិវៀតណាមកាត់ចិន ។ អ្នកស្រុក ហៅថាថៅកែថាក់ ឬ ចិកថាក់ចំពោះឡានខៀវ និង ថៅកែស៊ុង ឬ ចិកស៊ុងចំពោះឡានក្រហម ។ ការធ្វើដំណើរចម្ងាយសាមសិបគីឡូម៉ែត្រពីស្វាយពលទៅទីរួមខេត្តព្រៃវែង ត្រូវប្រើពេល ៣ ទៅ ៤ ម៉ោង ។ តាមផ្លូវ រថយន្តឈ្នួលត្រូវឈប់ជាញឹកញាប់ ដើម្បីដាក់អ្នកដំណើរ ឬ ដាក់ទំនិញផ្សេងៗរួមទាំងបន្លែ ផ្លែឈើ ឬ សត្វជ្រូក មាន់ ទា ទៀតផង ។

នៅតាមផ្លូវ គេឃើញវាលស្រែវែងឆ្ងាយ ដែលមានដើមត្នោតរាប់ពាន់ដើមដុះប្រូងប្រាងតាមក្លីរាប់គីឡូម៉ែត្រ ។ ជារឿយៗនៅពេលធ្វើដំណើរ ជួនកាលគេត្រូវចុះដើរទាំងអស់គ្នា ដើម្បីជួយសម្រាលទម្ងន់រថយន្ត នៅពេលណាដែលត្រូវឆ្លងអូរ ឬ ប្រឡាយទឹកម្ដងៗ បើពុំនោះទេរថយន្តអាចត្រូវជាប់គាំង ។ អ្នកដំណើរទាំងនោះត្រូវជួយរុញរថយន្តផងក៏មាន ។ នៅពេលឆ្លងកាត់ភូមិនីមួយៗ ជាពិសេសត្រង់ម្តុំភូមិព្រៃញ្ញៅ ពួកក្មេងតូចៗទាំងខ្លួនទទេរត់ប្រដេញគ្នា តាមពីក្រោយរថយន្ត ស្រែកហ៊ោរកញ្ជ្រៀវយ៉ាងសប្បាយ ក្នុងធូលីដីដែលហុយសំពោង ។ ក្មេងៗខ្លះរត់លោតតោងឈរនៅខាងក្រោយរថយន្ត អស់មួយស្របក់យ៉ាងរីករាយ ។ ខ្លួនប្រាណក្បាល មុខ មាត់របស់ពួកគេប្រឡាក់ប្រឡូសដោយធូលីសសំព្រុស នាំឲ្យមើលមិនស្គាល់ ។ ផ្លូវថ្នល់ទៅកាន់ទីរួមខេត្តនោះត្រូវបាន គេបររទេះគោ ឬ ក្របីពីលើទៀត

ផង ។

ផ្លូវពីស្នាយពល ទៅភ្នំពេញ ក៏មិនខុសគ្នាប៉ុន្មានដែរ ។ ក៏ប៉ុន្តែនៅសម័យនោះ ពុំមានរថយន្តចេញចូល ឬ ប្រើប្រាស់នៅឡើយទេ ។ ផ្លូវនោះជាផ្លូវតូចតាចដែលអ្នកជិះទោចក្រយានអាចធ្វើដំណើរបានដោយស្រួលផង អាចឈប់សំរាកស្រស់ស្រូបចំណីអាហារ ឬ ភេសជ្ជៈផង ដែលគេដាក់លក់តាមផ្លូវ ហូរហែជាប់រហូតមិនដូចផ្លូវពីស្នាយពល ទៅព្រៃវែងទេ ។ ផ្លូវពីស្នាយពល ទៅភ្នំពេញ[3]ត្រូវឆ្លងកាត់ទន្លេ និង ព្រែកជាច្រើន ជាពិសេស ឆ្លងកាត់ទន្លេតូចតាមស្ពានឫស្សីមួយ ។ ស្ពាននេះរលាស់ចុះឡើង នៅពេលគេដើរឆ្លងកាត់ម្តងៗ ។ ផ្លូវនេះនាំរហូតដល់ទន្លេធំ ឬ ទន្លេមេគង្គ នៅក្នុងខេត្តកណ្តាល ។ ម្យ៉ាងទៀត គេត្រូវឆ្លងកាត់ព្រៃស្តុបយ៉ាងវែងចាប់ពីភូមិកំពង់ចម្លង ភូមិព្រៃបាំង រហូតដល់ភូមិព្រះវិហារសួគ៌ ។ នៅពេលគេមកដល់ព្រែកតាមាក់ អ្នកដំណើរត្រូវឡើងកប៉ាល់បន្តដំណើរឆ្ពោះទៅភ្នំពេញ ។

នៅរដូវវស្សា ទាំងផ្លូវពីស្នាយពល ទៅទីរួមខេត្តព្រៃវែង ទាំងផ្លូវទៅភ្នំពេញមិនអាចធ្វើចរាចរណ៍បានឡើយ ដោយហេតុមានទឹកជំនន់ឡើងលិច ក្នុងរយៈពេលពីបីទៅបួនខែគឺ ពីខែ សីហា ទៅខែ វិច្ឆិកា ។ នៅពេលនោះ អ្នកស្រុកភូមិខ្ញុំធ្វើដំណើរតាមផ្លូវទឹក ។ ក្នុងសម័យនោះ មានតែពាណិជ្ជករពីរ ឬ បីនាក់ទេ ដែលប្រកបអាជីវកម្មដឹកជញ្ជូនតាមផ្លូវទឹកនេះ ។

កាណូតដឹកអ្នកដំណើរ និង ទំនិញត្រូវចំណាយពេលកន្លះថ្ងៃ ឬ ពេញមួយថ្ងៃ មុននឹងទៅដល់ទីក្រុងភ្នំពេញ អាស្រ័យដោយស្ថានភាពទឹកជំនន់គឺ ទឹកឡើង ឬ ទឹកស្រក ។ ការធ្វើដំណើរតាមកាណូតអាចធ្វើឲ្យកើតក្តីមនោរម្យក្នុងអារម្មណ៍ខ្លាំងណាស់ដោយសារទេសភាពធម្មជាតិគួរជាទីគាប់ភ្នែកដែលយើងឆ្លងកាត់ ។ ជាពិសេស នៅពេលដែលយើងទទួលទានអាហារម្តងៗ ម្ហូបដ៏ឆ្ងាញ់ពិសាររបស់យើង

[3] ផ្លូវនេះសព្វថ្ងៃ បានក្លាយជាកំណាត់មួយនៃផ្លូវជាតិលេខ៨ ដែលត្រូវបានពង្រីក និង ក្រាលកៅស៊ូយ៉ាងល្អស្អាត ។

ជាម្ហូបដ៏សាមញ្ញៗដូចជា៖ បាយខ្ចប់ស្លឹកឈូកជាមួយម៉ាំល្ហុង ឬ ជាមួយត្រីងៀតដុតជាដើម ។ តាមកាណូត យើងអាចមើលឃើញទំហំទឹកល្វឹងល្វើយវែងឆ្ងាយ ធំទូលាយដែលគួរឲ្យស្រមៃថា យើងកំពុងធ្វើដំណើរនៅក្នុងមហាសមុទ្រ ។ ពីខែ កញ្ញា ទៅខែ តុលា កំពស់ទឹកឡើងខ្ពស់ កន្លែងខ្លះខ្ពស់ស្មើរផុតចុងត្នោត ធ្វើឲ្យយើងមើលឃើញផ្ទៃទឹកនៅជាប់នឹងជើងមេឃ ។ នៅកន្លែងខ្លះ ទឹកឡើង លិចដល់ដំបូលផ្ទះ ។ នៅពេលធ្វើដំណើរ គេអាចប្រទះឃើញពពួកសត្វស្លាបចំរុះពណ៌ ហើររំលងយើងទាំងហ្វូងៗ ឬ ហែលលេងនៅក្បែរៗយើង ជាពិសេស ពួកសត្វទុងធំៗ ។ ត្រីក៏សម្បូណ៌ណាស់ដែរ ។ នៅរដូវទឹកស្រក តាមព្រែកនានា ពេលណាកាណូតយើងឆ្លងកាត់ ត្រីខ្លះលោតចេញពីទឹកផ្លោតចុះផ្លោតឡើង គួរឲ្យចង់ចុះទៅចាប់ ។ កាលសម័យនោះ យើងមិនទាន់ស្គាល់និយមន័យនៃពាក្យអេកូឡូស៊ី (Ecology) នៅឡើយទេ ។ នៅពេលទឹកស្រកខ្លាំង កាណូតបើកយឺតៗព្រោះត្រូវគេចជៀសមែកឈើតូចធំ នៅតាមមាត់ទឹកកុំឲ្យវាត់មកត្រូវអ្នកដំណើរ ។

## ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន

នៅក្នុងភូមិខ្ញុំ អ្នកស្រុកមួយចំនួនតែងមានទោចក្រយាន (កង់) និង ភាគច្រើនមានទូកតូចៗ ឬ ទូកសំប៉ាននៅប្រចាំគ្រួសារផង ។ អ្នកដែលមានម៉ូតូថែមទាំងមានទូក គេរាប់ថាជាអ្នកធូរធារ ឬ អ្នកមាន ។ ឪពុកម្តាយខ្ញុំមានទូក និង មានម៉ូតូ ក៏ប៉ុន្តែទូកយើងគ្មានម៉ាស៊ីនទេ[4] ។ ក្រោយមកក្នុងចុងទសវត្សរ៍ឆ្នាំ ១៩៦០ គ្រួសារណាដែលមានចាប់ពីផ្ទះឈើប្រក់ក្បឿងឡើងទៅ ហើយមានទូរទស្សន៍ មានម៉ូតូ និង ទូកម៉ាស៊ីន គ្រួសារនោះ អ្នកស្រុកឲ្យឈ្មោះថាគ្រួសារអ្នកមាន ។

[4] Cf. Roland Thomas, L’évolution économique du Cambodge (1900-1940), Thèse de Doctorat, Université de Paris 7, 1978, p. 142-144 (L’établissement des moyens de communications).

ភូមិស្នាយពលចែកជាពីរគឺៈ ភូមិស្នាយពលលើនៅខាងកើត និង ភូមិស្នាយពលក្រោមនៅខាងលិច ។ អ្នកភូមិស្នាយពលលើច្រើនប្រកបរបរធ្វើស្រែ ។ ពួកគាត់ចេញទៅធ្វើការតាំងពីព្រឹកព្រលឹមមុនថ្ងៃរះ ។ អ្នកស្រែច្រើនហៅរកគ្នាឲ្យជួយគ្នាទៅវិញទៅមក ។ គេប្រមូលគ្នាទាំងភូមិទៅជួយភ្ជួររាស់ដកស្ទូង ឬ ច្រូតកាត់ ។ គេជួយគ្នាម្តងម្នាក់ ដែលពួកអ្នកស្រុកហៅថាវេរប្រវាស់ដៃគ្នា ។ ជាទូទៅ គេបង្កើតបរិយាកាសសប្បាយរីករាយក្នុងការងារ ដោយមានបុរស និង ស្ត្រី ជាពិសេសកម្លោះក្រមុំ ធ្វើការផងច្រៀងតាមរបៀបចម្រៀងប្របកែផ្តោះផ្តងឆ្លើយឆ្លងគ្នាផង ដើម្បីបំបាត់ការនឿយហត់ ។ ក្រៅពីធ្វើស្រែ ប្រុសៗឡើងត្នោតយកទឹកត្នោតមកធ្វើស្ករ ឬធ្វើទឹកត្នោតជូរ ដែលជាភេសជ្ជៈពេញនិយមនាសម័យនោះ ។ នៅពេលទំនេររួចដៃពីស្រែចំការ ក្នុងចំណោមអ្នកស្រុកភូមិស្នាយពលលើ ពួកប្រុសៗច្រើនទៅធ្វើការជាជាងឈើ ឬ កម្មករសំណង់ នៅភូមិស្នាយពលក្រោម ព្រោះសេដ្ឋកិច្ចនៅទីនោះមានការលូតលាស់ចំរើនជឿនលឿនជាង ។ ចំណែកឯពួកស្រីៗជួយធ្វើការប្រុសៗ ដូចជាកូរស្ករ ឬ ត្បាញស្លឹកត្នោតធ្វើកន្ទេល ឬ ចាក់ស្មុកជាដើម ។

ផ្ទះសម្បែងនៅភូមិស្នាយពលលើភាគច្រើនៗធ្វើពីឈើ ឬ ឫស្សីប្រក់ស្លឹក តែគេក៏ឃើញមានផ្ទះឈើប្រក់ក្បឿងមួយៗដែរ ។ ក្នុងសម័យនោះ ពីភូមិស្នាយពលលើ ទៅភូមិស្នាយពលក្រោម មានចំងាយប្រមាណតែមួយគីឡូម៉ែត្រប៉ុណ្ណោះ ក៏ប៉ុន្តែ ចំពោះខ្ញុំដែលនៅតូច ចំងាយមួយគីឡូម៉ែត្រហាក់ដូចជាឆ្ងាយសម្បើមណាស់ ។

រវាងភូមិស្នាយពលលើ និង ភូមិស្នាយពលក្រោម ជីវភាពរស់នៅរបស់អ្នកស្រុក មានសភាពខុសគ្នាយ៉ាងដាច់ស្រឡះ ។ នៅភូមិស្នាយពលក្រោម គេឃើញមានផ្ទះឈើប្រក់ក្បឿង និង ផ្ទះថ្មមួយៗផង ។ ពាណិជ្ជករដែលមានសញ្ជាតិដើមជាជនជាតិចិន និង មន្ត្រីរាជការភាគច្រើនជាគ្រូបង្រៀនច្រើនរស់នៅភូមិស្នាយពល

ក្រោម ។ នៅក្នុងភូមិនេះ មានផ្សារមួយជាទីដែលអ្នកស្រុកមកពីភូមិជិតខាងនាំយកបន្លែ ត្រី សាច់ មកលក់ ។ ជារៀងរាល់ថ្ងៃ នៅម៉ោងប្រមាណ ៤ ឬ ៥ ទៀបភ្លឺ គេតែងឮសម្លេងជ្រូកស្រែករពោទ៏យ៉ាងទ្រហឹង កន្ទ្រាក់ស្មារតីអ្នកផងឲ្យភ្ញាក់ពីដំណេក ព្រោះចិនកាប់ជ្រូក ចាប់ផ្តើមចាក់កជ្រូក ដើម្បីយកសាច់មកលក់នៅទីផ្សារ ។ ចិនកាប់ជ្រូកធ្វើបែបនេះ ដើម្បីបង្ហូរឈាមស្រស់ និង ស្ងោរចំអិនទុកលក់ ។ ចិនកាប់ជ្រូកមិនមែនលក់តែសាច់ជ្រូកប៉ុណ្ណោះទេ តែគេក៏មានលក់គ្រឿងក្នុងផងដែរ ។ ចាប់ពីម៉ោង ៥ ឡើងទៅ មនុស្សចាប់ផ្តើមធ្វើដំណើរតាមផ្លូវធំទៅផ្សារស្នាយពលយ៉ាងគគ្រឹកគគ្រេង ។ ជាបន្តបន្ទាប់ អ្នកធ្វើដំណើរថ្មើរជើង ឬ ជិះកង់ ឬ ម៉ូតូ ដោយមានទូល ឬ ដឹកបន្លែបង្កា ត្រីសាច់ ឬ ទំនិញផ្សេងៗមកលក់មានចំនួនកាន់តែច្រើនឡើងៗ ។ អ្នកលក់រៀបចំទំនិញ បន្លែបង្កា ត្រី សាច់ សាច់ជ្រូក សាច់គោនៅលើគ្រែឫស្សី ។ ភាគច្រើន នៅផ្សារគេលក់ដូរតែម្ហូបម្ហាសំរាប់ទទួលទានតែប៉ុណ្ណោះ។ របស់របរឯទៀតដូចជា៖ ខោអាវ មុង ភួយ ប្រដាប់ប្រដាប្រើប្រាស់ ឬ ឧបករណ៍ធ្វើស្រែចំការ ត្រូវបានដាក់លក់តាមផ្ទះចិនជាហូរហែនៅតាមផ្លូវធំ ។ ផ្ទះលក់ដូររបស់របរទាំងនោះ ជារបស់ពាណិជ្ជករចិន ដែលចូលមករស់នៅក្នុងភូមិជាច្រើនជំនាន់មកហើយ ។ ចាប់ពីម៉ោង ៦ ទៅ ៧ ព្រឹកឡើងទៅ ទីផ្សារមានសភាពកុះករ និងកាន់តែកុះករឡើង ដោយសារតែពួកស្ត្រីមេផ្ទះនាំគ្នាមករកទិញបន្លែត្រីសាច់ ដើម្បីធ្វើម្ហូបប្រចាំគ្រួសារ ។ ជាធម្មតាស្ត្រីខ្មែរ ច្រើនចំណាយពេលមួយព្រឹក ឬ មួយល្ងាចដើម្បីធ្វើម្ហូប ។ ចាប់ពីម៉ោង ៩ ព្រឹកទៅទីផ្សារត្រូវរំសាយ ហើយក្លាយទៅជាទីស្ងប់ស្ងាត់ មិនអ៊ូអរគគ្រឹកគគ្រេងដូចពេលមុនឡើយ[5] ។

---

[5] Cf. Roland Thomas, L’évolution économique du Cambodge (1900-1940), op.cit, p. 156-164 (L’organisation commerciale: le Chinois).

# អ្នកស្រែខ្មែរ និង ពាណិជ្ជករចិន

ដោយសារបានកំរៃពីការលក់ដូរផលិតផលនៅទីផ្សារ អ្នកស្រែចាយលុយទិញទំនិញ និង របស់របរសំខាន់ៗតាមផ្ទះចិន មុននឹងត្រឡប់ទៅភូមិរៀងៗខ្លួនវិញ ។ ភូមិស្នាយពលមានភូមិតូចៗជាច្រើន នៅជុំវិញ ។ ភូមិនេះជាមជ្ឈមណ្ឌលពាណិជ្ជកម្មប្រចាំស្រុក ។ អ្នកស្រែមកពីភូមិទាំងនោះរៀងរាល់ថ្ងៃ ទាំងព្រឹក ទាំងល្ងាច ដើម្បីទិញអីវ៉ាន់យកទៅទុកប្រើប្រាស់ ។ អ្នកស្រែ និង ពាណិជ្ជករចិនទាំងនោះមានទំនាក់ទំនងគ្នាល្អណាស់ ។ គេអាចមកទិញអីវ៉ាន់ពេលណាក៏បាន យប់ក៏បាន ថ្ងៃក៏បាន ។ សំខាន់បំផុត បើមិនទាន់មានលុយ អ្នកស្រែក៏អាចទិញទំនិញ ឬ អីវ៉ែអីវ៉ាន់ពីពាណិជ្ជករចិនបានដែរ ដោយសារគេអាចជឿបណ្តាក់គ្នាបាន ។ ពេលយប់ គេអាចមកគោះទ្វារផ្ទះចិន ដើម្បីទិញរបស់របរ ដែលគេត្រូវការជាបន្ទាន់ដូចជា៖ ថ្នាំសង្កូវ ប្រេងកាត ឬ សំលៀកបំពាក់ ឬ ភេសជ្ជៈចាំបាច់ជាដើម ។ ពាណិជ្ជករចិនមិនប្រញាប់ប្រញាល់ទារប្រាក់ជំពាក់ភ្លាមទេ គេគ្រាន់តែកត់ត្រាទុករួច គេរង់ចាំរដូវច្រូតកាត់ រដូវប្រមូលផលក្នុងខែចុងឆ្នាំ ទើបគេទូទាត់គ្នាម្តង ។ ក៏ប៉ុន្តែ អ្នកស្រែត្រូវបង់ការប្រាក់ខ្ពស់ ដែលជួនកាលការប្រាក់នោះ កាន់តែកើនច្រើនឡើងៗបន្ថែមលើប្រាក់កម្ចីដើម ។ អ្នកស្រែច្រើនធ្វើការទូទាត់ប្រាក់ជំពាក់ទាំងដើមទាំងការនោះដែលគេគិតជារង្វាល់ស្រូវតាមចំនួនតៅ ឬ ថាំង[6] ។ ក្រោយដែលទូទាត់បំណុលរួចហើយ អ្នកស្រែច្រើនទុកផលស្រូវសេសសល់នៅក្នុងជង្រុក សំរាប់ទទួលទាន ឬ ទុកលក់បណ្តើរៗក្នុងរដូវខាងមុខ ។ ដូច្នេះ ប្រសិនបើផលស្រូវបានច្រើន អ្នកស្រែអាចនៅសល់ស្រូវច្រើនដែលគេអាចដូរយកខោអាវសំលៀកបំពាក់ ឬ របស់របរប្រើប្រាស់បានច្រើន ។ អ្នកស្រែសម័យនោះភាគច្រើន រកបានគ្រាន់តែសម្រាប់

---

[6] តៅ និង ថាំងជារង្វាស់រង្វាល់ខ្មែរពីបូរាណ ។ ជាធម្មតា ក្នុងមួយថាំង មានពីរតៅ ។

សងបំណុលចិនប៉ុណ្ណោះ ។

អ្នកស្រែមួយចំនួនមានដីធ្វើស្រែផង និង មានដីសំរាប់សង់ផ្ទះផង ។ ក៏ប៉ុន្តែ អ្នកស្រែខ្លះ មិនបានទទួលផលគ្រប់គ្រាន់ ពុំអាចឲ្យមានលទ្ធភាពសងបំណុលចាស់បាន ។ ដូច្នេះ ពីមួយឆ្នាំទៅមួយឆ្នាំ អ្នកស្រែនោះជំពាក់បំណុលចិនកាន់តែច្រើន ដែលនៅទីបញ្ចប់ត្រូវថៅកែចិនរឹបអូសយកដីធ្លីអស់ផង ។ ក្នុងករណីនេះ ពួកគាត់ត្រូវធ្វើស្រែប្រវាស់គ្នាជាមួយចិន ។ ពួកចិនជាអ្នកកំណត់តម្លៃទំនិញនៅទីផ្សារ ។ តម្លៃទីផ្សារឡើងចុះស្រេចទៅលើសហគមន៍ចិន ដែលមានខ្សែរយៈតាមបណ្តាញរបស់គេនៅទូទាំងប្រទេស ។ ថៅកែចិនជាអ្នកផ្តល់ទំនិញទៅដល់អ្នកភូមិ ទៅតាមប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ តាមការជាក់ស្តែង អ្នកស្រែជាអ្នកទិញ ជាអ្នកត្រូវការជានិច្ច រីឯថៅកែចិនជាអ្នកផ្តល់ ជាអ្នកផ្គត់ផ្គង់ ។ សេចក្តីត្រូវការរបស់អ្នកស្រែខ្មែរចេះតែកើនឡើងឥតឈប់ឈរ ដែលជាលេសឲ្យថៅកែចិន តម្លើងថ្លៃទំនិញជាប់ជាប្រចាំ ។

អ្វីដែលគួរកត់សំគាល់នៅក្នុងភូមិតូចដូចជាភូមិស្នាយពលនោះគឺ ភាពងាយស្រួលរបស់ជនជាតិចិន ក្នុងការបត់បែនសម្របសម្រួលធ្វើសមាហរណកម្មខ្លួនចូលមកក្នុងសង្គមខ្មែរ ។ ប្រសិនបើបុរសជនជាតិចិនខ្លះមិនទាន់អាចនិយាយភាសាខ្មែរបានច្បាស់ក៏ដោយ ក៏ប្រពន្ធ ឬ កូនចិនអាចនិយាយភាសាខ្មែរបានល្អឥតខ្ចោះដូចកូនចៅខ្មែរយើងដែរ ។ គ្រួសារជនជាតិចិននៅក្នុងភូមិ ច្រើនជាអ្នកកាន់ព្រះពុទ្ធសាសនា ។ យាយចាស់ៗច្រើនទៅវត្ត និង ជួយផ្គត់ផ្គង់ធ្វើបុណ្យទានតាមប្រពៃណីខ្មែរ ថែមពីលើប្រពៃណីចិនរបស់ពួកគេផ្ទាល់ទៀតផង ។

ពួកចិនបានរៀបការកូនស្រីរបស់គេជាមួយកូនកម្លោះខ្មែរ ដែលភាគច្រើនធ្វើជាមន្ត្រីរាជការ ។ គួររំលឹកថា អាពាហ៍ពិពាហ៍ខ្មែរ-ចិននេះបាននាំឲ្យមានកូនកាត់ជាច្រើន ដែលបានទាមទារសញ្ជាតិកម្ពុជា តាំងពីទសវត្សរ៍ឆ្នាំ ១៩២០ (ដើម្បីបង់

ពន្ធតិច)[7]។ នៅសម័យនោះ អ្នកស្រែមិនសូវចូលចិត្តបញ្ជូនកូនទៅរៀននៅសាលាទេ ព្រោះចង់ទុកកូនឲ្យជួយធ្វើស្រែ ឬ ឃ្វាលគោក្របី ។ ក៏ប៉ុន្តែ ចំពោះអ្នកស្រែខ្លះដែលមានលទ្ធភាពបញ្ជូនកូនទៅសាលា ពួកគាត់បានទទួលរង្វាន់មកវិញ ដោយកូនដែលបានបញ្ចប់ការសិក្សា បានទទួលការងារធ្វើក្នុងរាជការ ហើយកូននោះក៏ជួយទំនុកបំរុងតបស្នងសងគុណឪពុកម្តាយវិញដែរ ។

នៅទសវត្សរ៍ឆ្នាំ ១៩៥០ អ្នកដែលរៀនចប់សាលាបឋមសិក្សា[8] អាចចូលធ្វើគ្រូបង្រៀនបាន ។ នៅទសវត្សរ៍ឆ្នាំ ១៩៦០ អ្នកដែលរៀន និង ប្រឡងជាប់សញ្ញាប័ត្រឌីប្លូម[9] ទើបអាចប្រឡងធ្វើជាគ្រូបង្រៀន ។ ក៏ប៉ុន្តែអ្នកដែលមានសញ្ញាប័ត្រកាន់តែខ្ពស់ ក៏អាចចូលបំរើរាជការក្នុងមុខតំណែងកាន់តែធំ ។ ប្រាក់ខែរបស់គ្រូបង្រៀនមានប្រហែល ១០០ ដុល្លារ ក្នុងមួយខែ ដែលជាប្រាក់ខែខ្ពស់បង្គួរសំរាប់ប្រជាពលរដ្ឋខ្មែរក្នុងសម័យនោះ បើប្រៀបធៀបទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋធម្មតា ។ មុខរបរគ្រូបង្រៀនមានប្រជាប្រិយភាពខ្លាំងណាស់ដែលធ្វើឲ្យពួកចិននៅក្នុងភូមិ ចង់លើកកូនក្រមុំឲ្យ ។ លោកគ្រូកម្លោះៗដែលចេញមកធ្វើការដំបូង ពួកចិន ចង់លើកកូនឲ្យដោយសន្យាទិញម៉ូតូថ្មីជាចំណងដៃថែមទៀតផង ។ តាមធម្មតា ការងារនៅក្នុងរាជការត្រូវបានគេគោរពរាប់អានណាស់ ។ គ្រូបង្រៀនត្រូវបានពង្រាយទៅតាមភូមិនានាជាច្រើនទូទាំងប្រទេស ដូចនេះទើបពួកលោកគ្រូ ៗ ទទួលនូវការពេញនិយមជាទូទៅ ។

---

7 Sorn Samnang, L'évolution de la société cambodgienne entre les deux guerres mondiales (1919-1939), Thèse d'Histoire, Université Paris 7, Octobre 1995, p. 174.

8 អ្នកមាន វិញ្ញាបនបត្របញ្ចប់បឋមសិក្សា ដែលខ្មែរយើងសម័យនោះហៅថាជាប់ សេកទីហ្វីកា Certificat ។

9 ពាក្យឌីប្លូមនេះប្រែពីភាសាបារាំង Diplôme d'Etudes Secondaires du Premier Cycle (D.E.S.P.C) ដែលខ្មែរយើងហៅថា សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ឬ សញ្ញាបត្របញ្ចប់ការសិក្សាថ្នាក់ទី៩ (Grade 9) ។

# ភាពសុខដុមរមនាខាងជាតិសាសន៍ និង សាសនា

ការរស់នៅជាសហគមន៍ទាំងចិន ទាំងវៀតណាម ចាម និង ខ្មែរបាន ប្រព្រឹត្តទៅដោយសុខដុមរមនារវាងគ្នា និង គ្នាល្អណាស់ ។ ចិនៗ ទោះបីនៅជាអាណិជកជនបរទេសក៏ដោយ ក៏ត្រូវបានអ្នកស្រុកអ្នកភូមិ រាប់អានស្មើភាពគ្នា ដោយគ្មានប្រកាន់ជាតិសាសន៍អ្វីឡើយ ។

ក្រៅពីជនជាតិវៀតណាមកាត់ចិនពីរគ្រួសារ ដែលប្រកបរបរដើរឡានឈ្នួល មាន គ្រួសារពីរទៀតដែលរស់នៅក្នុងភូមិស្នាយពល ។ គ្រួសារមួយជាជាងកាត់ដេរខោអាវ និង មួយទៀតរកស៊ីចិញ្ចឹមជ្រូក ដាំបន្លែ និង លក់ម្ហូបអាហារវៀតណាម ជាពិសេស លក់បាញ់ហយ ។ អ្នកស្រុកភូមិយើងចាត់ទុកជនជាតិវៀតណាមជាអាណិកជនបរទេសខ្លាំងជាងពួកចិន ព្រោះពួកនេះមិនកាន់ព្រះពុទ្ធសាសនា និង មិនដែលទៅវត្តជាមួយពួកខ្មែរយើងម្តងណាឡើយ ។ ក្រៅពី ចិន និង វៀតណាម នៅមានជនជាតិចាមមួយគ្រួសារទៀតដែរ តែប្រហែលជាដោយសារពុំមានវិហារចាមបានជាគេមិនសូវឃើញពួកនេះនៅក្នុងភូមិ ។ យូរៗទៅគេក៏មិនឃើញមានជនជាតិចាមរស់នៅតទៅទៀតឡើយ ។ ដូច្នេះនៅទីបំផុត មុខរបរកាប់គោលក់សាច់ ក៏ត្រូវបានធ្លាក់មកជនជាតិខ្មែរវិញ ។ តាមធម្មតា ពួកចាមនាំគ្នាប្រកបរបរនេសាទត្រី ឬ កាប់គោយកសាច់លក់ ។ នៅភូមិស្នាយពល គេហាក់ដូចជាធ្វើការបែងចែកភារកិច្ចគ្នារវាងជនជាតិ ចិន ចាម និង វៀតណាម ក្នុងការប្រកបរបរចិញ្ចឹមជីវិត ។ ចិនៗលក់សាច់ជ្រូក ពួកចាមលក់សាច់គោ ។ សាសនារបស់ពួកចាមមិនអនុញ្ញាតឲ្យទទួលទានសាច់ជ្រូកទេ ។ ពួកចាមកាន់សាសនាឥស្លាម បានត្រូវចាត់ទុកជាជនជាតិខ្មែរពេញសិទ្ធិ ដែលគេហៅថា "ខ្មែរឥស្លាម" ។ តាមសៀវភៅប្រវត្តិសាស្ត្រដែលខ្ញុំបានអាន ជនជាតិចាមមានកំណើត នៅក្នុងប្រទេសមួយឈ្មោះ "ចម្ប៉ា" ដែល

បានត្រូវវៀតណាម វាយយកទឹកដី បំបាត់ចេញពីផែនទីពិភពលោកច្រើនរយឆ្នាំមកហើយ ។ ទីតាំងប្រទេសចម្ប៉ា ស្ថិតនៅចំតំបន់អណ្ដាមកណ្ដាលនៃប្រទេសវៀតណាមបច្ចុប្បន្ន ។ ព្រះចៅនៃប្រទេសចម្ប៉ាចុងក្រោយបង្អស់ និង សេនាវរេហ៍ពលរបស់ព្រះអង្គត្រូវបានភៀសខ្លួនមករស់នៅក្នុងប្រទេសកម្ពុជានៅឆ្នាំ ១៧២០[10] ។ នៅក្នុងភូមិស្នាយពលកាលសម័យមុនសង្គ្រាម ជនជាតិខ្មែរ ចិន វៀតណាម និង ចាម ឬ ខ្មែរឥស្លាម បានរស់នៅជាមួយគ្នាដោយសុខសាន្តពុំមានទំនាស់រវាងគ្នា និងគ្នាទេ ។

# ភាពស៊ីវិល័យនៃអ្នកភូមិស្នាយពលក្រោម

ភូមិស្នាយពលក្រោម ជាទីទំនាបនៅប៉ែកខាងលិច ស្ថិតនៅជាប់នឹងស្ទឹងមួយឈ្មោះថា៖ "ស្ទឹងស្នាយពល" ។ អ្នកភូមិខ្លះនៅតាមដងស្ទឹងប្រកបរបរនេសាទត្រី ។ អ្នកខ្លះទៀតប្រកបរបរលក់នំបញ្ចុក ។ ភូមិស្នាយពលមានឈ្មោះល្បីថាមាននំបញ្ចុកឆ្ងាញ់ ។ ដោយសារតែមានឈ្មោះល្បី "នំបញ្ចុកឆ្ងាញ់" យ៉ាងនេះ ទើបអ្នកទីក្រុងមួយចំនួនតែងនិយមធ្វើដំណើរ មកទិញយកទៅទទួលទានជាញឹកញាប់ ។ អ្នកស្រុកបី ឬ បួនគ្រួសាររកស៊ីលក់នំបញ្ចុក រហូតមានជីវភាពសមរម្យអាចបញ្ជូនកូនឲ្យទៅរៀននៅទីក្រុងភ្នំពេញបាន ។

អ្នកស្រុកខ្លះទៀត ប្រកបរបរដឹកអង្ករតាមទោចក្រយានទៅលក់ តាមភូមិនានា នៅជំនាមាត់ទន្លេធំ ។ អ្នករកស៊ីទាំងនោះគេទិញអង្ករ តាមរោងម៉ាស៊ីនកិនស្រូវ យកមកច្រកបាវក្រចៅ ១០០ គីឡូក្រាម រួចដឹកតាមកង់យកទៅលក់

[10] D G E Hall, A History of South-East Asia, Third Edition, London, 1968, p. 194.

តាមតំបន់មាត់ទន្លេ ចម្ងាយប្រមាណ ៤០ ឬ ៥០ គីឡូម៉ែត្រពីភូមិរបស់ខ្លួន ។ ពេលត្រឡប់មកផ្ទះវិញ អ្នកខ្លះទិញថ្នាំជក់យកមកថ្លឹងលក់រាយ តាមបណ្ដាភូមិនានានៅស្រុកស្រែ ។ អ្នករកស៊ីជឹកអង្ករលក់នោះ គេតែងនិយមហៅថាអ្នកឱបអង្ករ ។ ពួកគាត់ចេញពីផ្ទះទៅរកស៊ីតាំងពីព្រឹកនៅម៉ោង ៤ ឬ ៥ ជិតភ្លឺ ដោយជឹកអង្ករយកទៅលក់ហូរហែចាប់ពីភូមិព្រែកតាមាក់ ក្នុងស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល រហូតតាមដងទន្លេធំ ។ ពួកស្ត្រីជាប្រពន្ធត្រៀមសារ៉ុង និង សាប៊ូទុកឲ្យប្ដីងូតទឹកសម្អាតខ្លួន និង សម្រាកនៅពេលត្រឡប់មកវិញ នៅប្រមាណម៉ោង ៣ ឬ ៤ រសៀល ។

អ្នកភូមិស្នាយពលក្រោម រស់នៅរបៀបស៊ីវិល័យ មិនខុសពីអ្នកទីក្រុងឡើយ ។ អ្នកស្រុកទាំងនោះចូលចិត្តលេងភ្លេង ច្រៀងរាំ និង លេងកីឡាប្រជាប្រិយដូចជា កីឡាបាល់ទាត់ ឬ កីឡាបាល់ទះជាដើម ។ នៅពេលបុណ្យចូលឆ្នាំខ្មែរនាពាក់កណ្ដាលខែ មេសា រៀងរាល់ឆ្នាំ អ្នកស្រុកនាំគ្នាច្រៀងរាំតាមផ្លូវបីយប់បីថ្ងៃយ៉ាងសប្បាយអឺងកង ។ ពួកគេច្រើននាំគ្នារាំវង់ ខ្លះហៅថារាំឡាំធនដោយមានឧបករណ៍ភ្លេងដែលគេមានរៀងៗខ្លួន ដូចជាស្គរ(ស្គរដី) ម៉ង់ដូលីន អាកកដេអុង និង ហ្គីតាជាដើម ។

មន្ត្រីរាជការសោលាស្រុកភាគច្រើន មានទីលំនៅៗភូមិស្នាយពលក្រោម ។ ដូច្នេះអ្នកភូមិនេះ សម្បូណ៌ដោយអ្នកធូរធារ ដែលតែងនិយមមកទទួលទានអាហារពេលព្រឹកនៅហាងគុយទាវតែមួយគត់ នៅជិតមាត់ស្ទឹងស្នាយពល ។ មន្ត្រីម្នាក់ដែលទទួលខុសត្រូវផ្នែកគណនេយ្យប្រចាំស្រុក បានត្រូវអ្នកស្រុកឲ្យឈ្មោះថា៖ "ចឺដោយ" ។ ចឺដោយមានបើករោងល្ខោនបាសាក់ ដែលសម្ដែងរៀងរាល់ល្ងាចនៅគ្រប់រដូវ ។

ក្រុមល្ខោនបាសាក់នេះមានសិល្បករ សិល្បការិនីពី ១០ ទៅ ២០ នាក់ បើគិតរួមទាំងអ្នកភ្លេងផង ។ ជារៀងរាល់ថ្ងៃ រវាងម៉ោង ៣ ឬ ៤ ល្ងាច តួសម្តែង ៣ ឬ ៤ នាក់ ក្នុងសម្លៀកបំពាក់ជាតួអង្គដែលត្រូវសំដែងក្នុងសាច់រឿង ជិះរទេះគោក្រោយមក ជិះរ៉ឺម៉ក់ម៉ូតូ មកបាចសំបុត្រឃោសនាតាមផ្លូវធំ ដោយវាយស្គរប្រកូកប្រកាស ឲ្យអ្នកស្រុកទៅមើលល្ខោន ដែលពួកគេនឹងសម្តែងនៅពេលយប់ ។ ចាប់ពីម៉ោង ៦ ល្ងាចទៅ ស្គរធំរោទ៍យ៉ាងខ្លាំងញាប់តន្លើនជាប់រហូតគ្មានដាច់ ដែលគេអាចស្តាប់ឮតាំងពីចម្ងាយ ។ ស្នូរស្គរល្ខោនរោទ៍យ៉ាងរញ្ជួយដីនោះ ទាញកន្ទ្រាក់អារម្មណ៍អ្នកស្រុក ឲ្យមីម្នានាំគ្នាទៅមើលល្ខោន ។ សំបុត្រចូលមើលល្ខោនសម័យនោះតម្លៃខ្ពស់ជាងគេគឺ ១០ រៀល ស្មើនឹង ៣ កាក់ដុល្លារសហរដ្ឋអាមេរិក ។ ឯតម្លៃទាបបង្អស់គឺ ១ រៀល សម្រាប់អង្គុយលើក្តារបន្ទះនៅខាងក្រោយ ដែលគេរៀបជាថ្នាក់ៗពីខ្ពស់ទៅទាប មួយកាំទាបបន្តិចមួយកាំទាបបន្តិច ឆ្ពោះទៅរកឆាកនៅខាងមុខ ។ កន្លែងខ្ពស់ជាងគេនៅខាងក្រោយបង្អស់មានកំពស់ជិត ៣ ម៉ែត្រ ដែលគេនិយមហៅថាថ្នាក់ "ឡូស" ។

រាល់ល្ងាចនៅពេលឮសូរស្គររោទ៍កាលណា ពួកយើងក្មេងៗទាក់ជើង ចង់ទៅមើលល្ខោនស្ទើរទ្រាំពុំបាន តែងតែទាញដៃទាញជើងឪពុកម្តាយឲ្យនាំទៅមើលការសម្តែងសិល្បៈដ៏ប្រជាប្រិយនេះ ។ បើឪពុកម្តាយមិននាំទៅទេ ក្មេងៗខ្លះលួចទៅមើលដោយខ្លួនឯង ។ បើគ្មានលុយទេ គេលបហែកជញ្ជាំងស្លឹករួចលូនឡើងទៅអង្គុយលើថ្នាក់ "ឡូស" ក្រោយបង្អស់ ។ នៅពេលត្រូវសម្តែងរឿងថ្មីអ្នកដឹកនាំរឿង តែងប្រមូលសិល្បករមកប្រជុំដែលគេហៅថា៖ "សមរឿង" ។ អ្នកដឹកនាំរឿងចែកតួអង្គឲ្យសិល្បករម្នាក់ៗសម្តែងតាមសាច់រឿង ដោយគាត់គ្រាន់តែនិទានត្រួសៗឲ្យសិល្បករទាំងអស់ស្តាប់ ។ សិល្បករម្នាក់ៗ បញ្ចេញនូវទេពកោសល្យរបស់ខ្លួនដោយមិនចាំបាច់អានអត្ថបទណាមួយឡើយ ។ ពេលគេត្រូវនិយាយ ឬ

ច្រៀង គេនិយាយ ឬ ច្រៀងតាមការប៉ិនប្រសប់របស់គេម្នាក់ៗ ។ ខ្ញុំក៏ដូចជាកុមារឯទៀតមួយចំនួនដែរ តែងតែមកមើលគេសមរឿងមិនដែលខាន ព្រោះនៅពេលនោះ យើងអាចមើលឃើញ តួឯកប្រុសស្រី តួយក្ស ឬ តួកំប្លែងដោយផ្ទាល់ក្នុងភាពធម្មតា មិនតែងតួដូចយើងឃើញនៅពេលសម្តែងលើឆាកនោះទេ ។

សិល្បករនាសម័យនោះ មានជីវភាពមិនសូវធូរធារប៉ុន្មានឡើយ ។ តួយក្សដែលមានឈ្មោះល្បីដូចជាតួយក្សឈ្មោះ យក្សខេងជាដើម តែងតែដើរបបក់កង្កែបនៅពេលថ្ងៃ ដើម្បីយកមកធ្វើជាម្ហូបបន្ថែម ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់គាត់ ។ ជាទូទៅ សិល្បៈល្ខោនបាសាក់ មានប្រជាប្រិយភាពណាស់ ក៏ប៉ុន្តែសិល្បករខ្មែរមិនត្រូវទទួលបាននូវការគោរពរាប់អាន ដូចសិល្បករនៅលោកខាងលិចឡើយ ។ រហូតពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៦០ រោងល្ខោនជាមជ្ឈមណ្ឌលកែកំសាន្តតែមួយគត់នៅក្នុងស្រុកពារាំងរបស់យើង ។ ក៏ប៉ុន្តែ បន្តិចម្តងៗដោយសារឥទ្ធិពលនៃទូរទស្សន៍ ដែលបានជ្រៀតចូលតាមលំនៅដ្ឋានរបស់ប្រជាពលរដ្ឋជាលំដាប់នោះ ល្ខោនបាសាក់របស់យើង ក៏កាន់តែបាត់បង់នូវប្រជាប្រិយភាពបន្តិចម្តងៗ រហូតដល់ត្រូវបិទរោងឈប់សម្តែងរៀងរហូត ចាប់ពីចុងទសវត្សរ៍ឆ្នាំ ១៩៦០ មក ។

នៅភូមិស្នាយពលក៏ដូចជានៅភូមិនានា ក្នុងប្រទេសកម្ពុជាយើងដែរព្រះពុទ្ធសាសនាមានការរីកសុះសាយល្អណាស់[11] ។ វត្តអារាមជាមជ្ឈមណ្ឌល ឬ ទីប្រជុំនៃសកម្មភាពសង្គមកិច្ចទាំងឡាយ ។ គេនិយមទៅធ្វើបុណ្យទាន ឬ ពិធីធំៗនៅក្នុងវត្ត ។ អ្នកភូមិយើងតែងនិយមទៅធ្វើបុណ្យនៅវត្តស្នាយពល ឬ វត្តរកាដែលស្ថិតនៅក្នុងភូមិមួយក្បែរភូមិស្នាយពល ។ ជីដូនជីតា និង ឪពុកម្តាយខ្ញុំ តែងតែទៅធ្វើបុណ្យនៅវត្តរកាជាប់ជានិច្ច ដោយសារព្រះគ្រូចៅអធិការជាគ្រូផង និង ជាមិត្តជិតស្និទ្ធ

[11] Cf. Sorn Samnang, L’évolution de la société cambodgienne entre les deux guerres mondiales (1919-1939), op.cit, p. 301-319.

ប្រចាំគ្រួសារយើងផង ។ យើងប្រគេនព្រះនាមព្រះចៅអធិការថាៈ "លោកតាវត្តកោ" ។ យាយៗ តាៗ ដែលគោរពប្រតិបត្តព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនតែងទៅវត្តរៀងរាល់ថ្ងៃសីល ដើម្បីទៅសុំសីល ឬ ស្តាប់ព្រះសង្ឃសំដែងធម្មទេសនា ។ ចំពោះពួកយើងក្មេងៗ យើងបានទទួលការអប់រំឲ្យយល់ថា ព្រះពុទ្ធសាសនាមានលក្ខណៈសាមញ្ញជាទីបំផុតគឺ នៅលើមេឃមានទេវតាចាំកត់ត្រាទុកនូវទង្វើរបស់យើងម្នាក់ៗ ។ បើយើងធ្វើល្អ យើងនឹងបានឡើងឋានសួគ៌ តែបើយើងធ្វើអាក្រក់ យើងនឹងចុះនរកតាមបញ្ជីកត់ត្រារបស់ទេវតានោះ ។

# វង្សត្រកូលខ្ញុំ

ភូមិដែលខ្ញុំចាប់កំណើតស្ថិតនៅចន្លោះភូមិស្នាយពលលើ និង ភូមិស្នាយពលក្រោមដែលនាសម័យនោះមានផ្ទះតែ ៤ ឬ ១០ ខ្នងប៉ុណ្ណោះ ។ ជីតាខ្ញុំខាងម្តាយសង់ផ្ទះនេះ តាំងពីទសវត្សរ៍ដំបូងនៃសតវត្សទី ២០ មកម្ល៉េះ ។ ផ្ទះនោះជាផ្ទះឈើប្រក់ក្បឿង ប្រកបដោយសសរមូលធំៗខ្មៅរលោង ។ ជញ្ជាំងឈើត្រូវបានធ្វើពីក្តារប្រណិតបិទផ្ជិតភ្ជាប់គ្នា តាមបច្ចេកទេសមួយ ដែលគេមិនអាចមើលឃើញដែកគោលមួយគ្រាប់ណាឡើយ ។ នៅខាងមុខ មានយ៉ដែលមានបង្កាន់ដៃឈើព័ទ្ធជុំវិញ ។ នៅផ្នែកខាងក្រោយ មានផ្ទះបាយដាច់ដោយឡែកពីផ្ទះធំ ។ ពេលឡើងជណ្តើរទៅខាងលើ និង ឆ្លងកាត់យ៉នោះចូលទៅខាងក្នុង គេឃើញទូរឈើធំពីរសង់ជាជញ្ជាំងបាំងចែកបន្ទប់ធំៗជាស្រេច ម្ខាងឆ្វេងម្ខាងស្តាំ ដោយមានឆ្លាក់ក្បាច់រចនាលំអផង ។ ផ្ទះនេះជាកម្មសិទ្ធិរបស់ជីតាខ្ញុំខាងម្តាយ ឈ្មោះលោកតា យិន អ៊ុច ។

លោកតា យិន អ៊ុច ជាមន្ត្រីមានមុខមានមាត់ប្រចាំភូមិស្រុក ដោយសារតែ

បានបម្រើរាជការក្នុងមុខតំណែងផ្សេងៗអស់ជាយូរឆ្នាំមកហើយ ។ ដំបូងគាត់ធ្វើជាមេឃុំ បន្ទាប់មក ជាសមាជិកក្រុមប្រឹក្សាពិគ្រោះយោបល់នៃព្រះរាជាណាចក្រកម្ពុជា ជាចៅនិគម និង នៅចុងក្រោយជាអាជ្ញាសាលា ។ ខ្ញុំមិនបានស្គាល់ជីតារបស់ខ្ញុំនេះទេ ព្រោះគាត់ធ្វើមរណៈកាលទៅហើយ កាលខ្ញុំកំពុងនៅជាទារកនៅឡើយ ។ ជីតាខ្ញុំរស់នៅជាបែបអភិជន ។ គាត់ធ្វើដំណើរតាមរទេះសំឡី ដែលមានអ្នកបររទេះជូនគាត់ និង មានខ្ញុំបំរើនៅចាំបម្រើគាត់ជាប្រចាំ ។ លោកតា ឃិន អ៊ុច រៀបអាពាហ៍ពិពាហ៍ជាមួយជីដូនខ្ញុំឈ្មោះលោកយាយ អ៊ុង គូ ។ លោកយាយលោកតាមានកូនទាំងអស់ ៧ នាក់គឺស្រី ៥ នាក់ និង ប្រុស ២ នាក់ ។ ម្ដាយរបស់ខ្ញុំឈ្មោះ សុខា ជាកូនទី ៣ ។

កូនស្រីទាំង ៥ នាក់របស់លោកយាយលោកតា សុទ្ធតែបានទៅរៀននៅសាលាបឋមសិក្សាទាំងអស់ ។ ក៏ប៉ុន្តែ មានតែម្ដាយមីងខ្ញុំឈ្មោះ សាម៉ុឌី ទេ ដែលបានធ្វើជាគ្រូបង្រៀន ចំណែកឪពុកមាខ្ញុំពីរនាក់នោះ សុទ្ធតែបានរៀនខ្ពស់តទៅទៀតហើយ បានទទួលមុខតំណែងដ៏សមគួរក្នុងមុខងារសាធារណៈ ។ ក្នុងសម័យមុនខ្ញុំកើតនោះ ជាទូទៅឪពុកម្ដាយមិនចង់បញ្ជូនកូនស្រីឲ្យទៅរៀននៅសាលាទេ ។ ឪពុកម្ដាយខ្លះ ទុកកូនស្រីនៅផ្ទះដើម្បីឲ្យរៀនធ្វើស្ត្រីមេផ្ទះ សម្រាប់អនាគតរបស់នាង ។ ឪពុកម្ដាយខ្លះអាចបារម្ភថាមិនអាចឃុំគ្រងកូនស្រីបាន ប្រសិនបើបណ្ដោយឲ្យទៅរៀននៅសាលា ក្រៅពីក្រសែភ្នែករបស់ពួកគាត់ ។ ម្ដាយខ្ញុំមិនបានរៀនចប់បឋមសិក្សាទេ តែគាត់អាចអាន និង សរសេរបាន ។

ឪពុកម្ដាយជំនាន់បូរាណចិញ្ចឹមបីបាច់ថែរក្សា និង អប់រំកូនស្រីឲ្យដើរតាមគន្លងប្រពៃណីយ៉ាងហ្មត់ចត់ត្រឹមត្រូវជាទីបំផុត ។ កូនស្រីៗ ពេលពេញក្រមុំត្រូវស្ថិតនៅក្នុងម្លប់ មិនឲ្យត្រូវកំដៅថ្ងៃដែលនាំឲ្យខូចសម្រស់ ។ ប្រសិនបើដើរទៅណាមកណាត្រូវមានចាស់ទុំទៅជាមួយ ។ នារីក្រមុំមិនត្រូវនិយាយជាមួយប្រុសៗ

ឡើយ ។ បើត្រូវរៀបអាពាហ៍ពិពាហ៍ ឪពុកម្តាយជាអ្នករើសគូស្រករឲ្យ និង សម្រេចថាត្រូវរៀបការ ឬ មិនត្រូវរៀបការ ។ កូនកម្លោះ និង កូនក្រមុំ មិនចាំបាច់ស្គាល់គ្នាពីមុនមកទេ ស្រេចលើឪពុកម្តាយជាអ្នកទុកដាក់ទាំងស្រុងតែម្តង ។ តាមធម្មតាគ្រួសារខាងកូនប្រុសជាអ្នកចូលទៅស្តីដណ្តឹង ។ ប្រសិនបើយល់ព្រម គ្រួសារកូនស្រីនឹងបង្គាប់ឲ្យខាងកូនប្រុសនាំមកនូវមាសប្រាក់ ស្រូវអង្ករទុកជាជំនូនជូនដល់ខាងកូនស្រី ។ បន្ថែមពីលើជំនូននោះ កូនប្រុសត្រូវមកនៅបម្រើខាងកូនស្រីមួយរយៈពេល អ្នកខ្លះមួយឆ្នាំ អ្នកខ្លះពីរឆ្នាំ ឬ លើសពីនេះ អាស្រ័យលើលក្ខខណ្ឌដែលគ្រួសារខាងស្រីកំណត់ ។ ក្នុងពេលដែលកូនប្រុសមកបម្រើខាងស្រីនេះ បើអនាគតឪពុកក្មេក ឬ ម្តាយក្មេកមិនពេញចិត្តនឹងការងារ ឬ កិរិយាមារយាទរបស់កូនប្រុសនោះទេ គ្រួសារខាងស្រីអាចផ្តាច់ឈប់ឲ្យរៀបការ ដោយមិនចាំបាច់សងជំនូនទៅខាងប្រុសវិញក៏បាន ។ ឪពុកនិងម្តាយខ្ញុំ បានគ្នាជាគូស្រករក្នុងបរិបទនៃប្រពៃណីខ្មែរពីបរមបូរាណយ៉ាងនេះ ។ កាលនោះ ខ្មែរយើងនៅកាន់ប្រពៃណីតឹងតែងណាស់ មិនដូចទសវត្សរ៍ឆ្នាំ ១៩៦០ ដែលពួកចិនៗលើកកូនក្រមុំឲ្យលោកគ្រូៗ ខ្មែរដោយស្រួលៗនោះទេ។

ឪពុកខ្ញុំឈ្មោះ អៀង មុត ។ គាត់កើតនៅភូមិមេសប្រចាន់ ដែលជាប់នឹងទន្លេតូច ។ គ្រួសារឪពុកខ្ញុំជាគ្រួសារកសិករ ហើយសុទ្ធតែបានបួសរៀនតាមផ្លូវព្រះពុទ្ធសាសនា ។ ជីតាខ្ញុំឈ្មោះលោកតា គង់ អៀង ឯជីដូនខ្ញុំឈ្មោះ លោកយាយ ហ៊ូ ឱ ។ លោកយាយលោកតាមានកូន ៦ នាក់ ប្រុស ៤ នាក់ ស្រី ២ នាក់ ។ ឪពុកខ្ញុំជាកូនទី ៤ ។ ក្រៅពីកូនស្រីទាំងពីរនាក់ចេញ កូនប្រុសទាំងបួនរបស់លោកយាយលោកតាសុទ្ធតែបានបួសជាភិក្ខុសាមណេរទាំងអស់ ។ តាមធម្មតា ក្មេងៗច្រើនទៅនៅវត្ត រហូតអាយុបាន ១៣ ទៅ ១៥ ឆ្នាំ គេនាំគ្នាបួសជាសាមណេរ ។ នៅវត្ត ពួកសាមណេរ ឬ ពួកលោកនេន រៀនធម៌អាថ៌ព្រះពុទ្ធសាសនាផង រៀន

អក្សរសាស្ត្រ លេខនព្វន្ត រៀនក្បាច់គិតលេខ[12]ដូចចិនផង ឬ រៀនធ្វើជាង ជាងឈើ ជាងកំបោរ[13]ជាដើម ។ល។ រហូតដល់ព្រះជន្ម (អាយុ) ១៨ ព្រះវស្សា (ឆ្នាំ) ។ ក្នុងចន្លោះអាយុ ១៨ និង ២១ ឆ្នាំ គេអាចលាចាកសិក្ខាបទ ឬ សឹក (តាមពាក្យសាមញ្ញ) មកជាគ្រហស្ថរស់នៅជួយធ្វើការឪពុកម្តាយ ដូចយុវជនឯទៀតបាន ។ តែសាមណេរខ្លះ ក៏នៅបន្តភេទជាសង្ឃតទៅទៀត ដោយគ្រាន់តែបំពេញបន្ថែមឲ្យទៅជាភិក្ខុពេញលក្ខណៈ ។ ភិក្ខុអាចស្ថិតនៅជាសង្ឃរហូតមួយជីវិត ឬ អាចលាចាកសិក្ខាបទមកជាពលរដ្ឋធម្មតានៅពេលណាមួយក៏បាន ។ លោកនេនដែលលាចាកសិក្ខាបទ គេច្រើនហៅ "ជី" រីឯភិក្ខុដែលលាចាកសិក្ខាបទហៅថា "អន្ទិត" តាមពាក្យសាមញ្ញធម្មតារបស់អ្នកស្រុក ឬ ហៅថាបណ្ឌិត តាមពាក្យវប្បធម៌ ។

ឪពុកខ្ញុំ និង ឪពុកធំខ្ញុំទាំងអស់សុទ្ធតែបានបួសជាភិក្ខុ ។ បងបង្អស់របស់ឪពុកខ្ញុំឈ្មោះ អៀង ប៊ុន ស្ថិតនៅជាសង្ឃ គង់នៅវត្តសារវន្តតេជោក្រុងភ្នំពេញរហូតដល់ឆ្នាំ ១៩៧៤ ទើបលោកសុគត ។ អាយុ ២៨ ឆ្នាំ ឪពុកខ្ញុំលាចាកសិក្ខាបទពីភិក្ខុមកនៅជួយធ្វើការម្តាយដែលនៅមេម៉ាយ ក្រោយពីជីតាខ្ញុំបានចូលមរណកាលទៅ ។ ដល់គាត់មានអាយុ ៣០ ឆ្នាំ ឪពុកខ្ញុំជាកម្លោះចាស់ នៅពេលដែលម្តាយខ្ញុំទើបមានអាយុតែ ១៨ ឆ្នាំប៉ុណ្ណោះ ។ គ្រួសារខាងឪពុក និង ម្តាយខ្ញុំបានត្រូវរ៉ូវគ្នា ដើម្បីរៀបចំឲ្យអ្នកទាំងពីរបានគ្នាជាប្តីប្រពន្ធតទៅ ។ ដោយសារគ្រួសារខាងឪពុកខ្ញុំមានសភាពអន់ខ្សោយជាង គាត់ត្រូវទទួលបង្គាប់យ៉ាងធ្ងន់ និង ត្រូវមកធ្វើការបម្រើគ្រួសារខាងម្តាយខ្ញុំ ក្នុងរយៈពេលមួយឆ្នាំ មុននឹងរៀបការ ។ ក្នុងរយៈ

[12] ក្បាច់ជាឧបករណ៍គិតលេខរបស់ពាណិជ្ជករចិន ដែលគេអាចប្រើធ្វើលេខ បូក ដក គុណ ចែក ក្នុងសម័យដែលមិនទាន់មានម៉ាស៊ីនគិតលេខទំនើប ។

[13] កាលជំនាន់ដើម គេហៅជាងកំបោរ ឥឡូវគេហៅ ជាងស៊ីម៉ង់ ។

ពេលមួយឆ្នាំនេះ ឪពុកខ្ញុំត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ដោយអត់ខ្លាចនឿយហត់ឡើយ ។ ក្នុងរយៈពេលនេះ គាត់មិនអាចនិយាយលេង ឬ ទៅណាមកណាជាមួយគូដណ្តឹងគាត់ឡើយ ។ នៅទីបញ្ចប់ ឪពុក និង ម្តាយខ្ញុំបានរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ ១៩៤៥ ។ ការមកធ្វើការបម្រើអនាគតឪពុកក្មេកម្តាយក្មេក ជាបទពិសោធន៍ដ៏ល្អសំរាប់ឪពុកខ្ញុំ ព្រោះជីតាខ្ញុំគឺ លោកតា យិន អ៊ុច មានការពេញចិត្តចំពោះការងាររបស់អនាគតកូនប្រសារគាត់ជាទីបំផុត ។

ក្រោយពីរៀបការហើយ ឪពុកខ្ញុំបានទទួលការបំពាក់បំប៉នវិជ្ជាផ្នែកច្បាប់ ជាពិសេសច្បាប់រដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌ និង នីតិក្រមនានាពីជីតាខ្ញុំ ។ ក្រោយពីបានទទួលការបំពាក់បំប៉នផ្នែកច្បាប់រួចមក ឪពុកខ្ញុំបានទទួលមរតកពីជីតាខ្ញុំ ដោយត្រូវបានទទួលការតែងតាំងជាអាជ្ញាសាលា ។ កាលសម័យមុនសង្គ្រាមនោះ មុខងារអាជ្ញាសាលាជាមុខងារក្នុងវិជ្ជាជីវៈសេរី ដែលមានមុខនាទីសម្រេចអនុវត្តសាលក្រមរបស់តុលាការ ជាពិសេសផ្នែករដ្ឋប្បវេណី និង ធ្វើការប្រគល់ដីការកោះដល់គូក្តីឲ្យចូលរួមសវនាការរបស់តុលាការ ។ នៅសម័យនោះ មុខតំណែងអាជ្ញាសាលាខុសពីមុខតំណែងព្រះរាជអាជ្ញា ព្រោះតំណែងអាជ្ញាសាលាអាចផ្ទេរពីឪពុកទៅកូនបាន ។ ប៉ុន្តែក្រោយមក មុខតំណែងនេះត្រូវឆ្លងកាត់ការប្រឡងវិជ្ជាជីវៈទូទាំងប្រទេសដោយមានគណៈមេប្រយោគ ដែលក្នុងនោះមានចៅក្រមជាន់ខ្ពស់ជាសមាជិក និង មានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាប្រធាន ។ ឪពុកខ្ញុំបានទទួលកាន់តំណែងជាអាជ្ញាសាលា នៅឆ្នាំ ១៩៤៩ ។ មួយឆ្នាំកន្លងមក លោកតា យិន អ៊ុច ក៏ទទួលមរណភាពលាចាកយើងទៅ ។

នៅប្រទេសខ្មែរយើងៗដាក់ឈ្មោះត្រកូលមុនឈ្មោះយើងផ្ទាល់ មិនដូចនៅប្រទេសលោកខាងលិចឡើយ ។ ឪពុកខ្ញុំដាក់ឈ្មោះជីតាខ្ញុំនៅខាងមុខ ដូច្នេះឈ្មោះគាត់គឺ អៀង មុត ។ តាមការនិយាយរ៉ាយរ៉ាប់របស់ឪពុកខ្ញុំ លោកតា អៀង

មានបទពិសោធន៍យ៉ាងច្រើនក្នុងជីវិតរបស់គាត់ ។ កាលគាត់នៅក្មេង គាត់រៀនក្បាច់គុន ហើយមានការប៉ិនប្រសប់ក្នុងការប្រើដំបង ។ កាលចុងសតវត្សទី ១៩ ឪពុកមាម្នាក់របស់កម្លោះ អៀង ធ្វើជាមេឃុំ ។ លោកមេឃុំមានកម្រិតវិជ្ជាគុនដំបងយ៉ាងជំនាញដែលគេទទួលស្គាល់ថាគាត់ជាគ្រូគុននិយម ។ ប្រហែលជាដោយយល់ឃើញថា អ្នកចេះវិជ្ជាគុននិយមអាចទទួលគ្រោះថ្នាក់ដោយសារវិជ្ជានេះ ទើបលោកមេឃុំហាមប្រាមកូនក្មួយទាំងអស់ មិនឲ្យទៅហាត់រៀនវិជ្ជានេះឡើយ ។ តែប្រសិនបើលោកមេឃុំដឹងថា មានកូនក្មួយណាមួយហ៊ានចចេសលួចទៅរៀន គាត់នឹងដេញចេញ មិនឲ្យរស់នៅក្នុងភូមិជាមួយគាត់ឡើយ ។ បើចង់មករស់នៅក្នុងភូមិវិញ ទាល់តែកូនក្មួយនោះប្រយុទ្ធឈ្នះគាត់ទើបបាន ។ បើមិនឈ្នះត្រូវតែនិរទេសខ្លួនចេញ ។

ជាច្រើនលើក យុវជន អៀង តែងលួចទៅរៀនវិជ្ជាគុន ហើយជាច្រើនលើកលោកឪពុកមាជាមេឃុំតែងហៅយុវជន អៀង ឲ្យមកល្បងថ្វីដៃជាមួយគាត់ ។ ម្តងៗយុវជន អៀង តែងតែប្រកួតចាញ់លោកមាមេឃុំ ហើយតែងត្រូវនិរទេសទៅនៅស្រុកផ្សេង ។ ប៉ុន្តែនៅលើកចុងក្រោយ គាត់បានដើរស្វែងរករៀនវិជ្ជាគុនពីស្ត្រីគ្រូគុនម្នាក់អាយុប្រមាណ ៣០ ឆ្នាំ នៅស្រុកលើ (ពួកអ្នកស្រុកយើង តែងនិយមហៅអ្នកស្រុកនៅចាប់ពី ពាមជាំង ទៅមេមត់ ក្នុងខេត្តកំពង់ចាមថាអ្នកស្រុកលើ) ។ យុវជន អៀង បានហាត់រៀនឈានដល់កម្រិតគុននិយមខ្ពស់ និង ល្មមគ្រប់គ្រាន់អាចប្រកួតជាមួយលោកមេឃុំជាឪពុកមាបាន ។ នៅលើកនេះ កម្លោះ អៀង ឈ្នះហើយត្រូវបានអនុញ្ញាតឲ្យរស់នៅក្នុងស្រុកជាធម្មតាវិញ ។ ដោយសារវិជ្ជាគុននិយមរបស់គាត់ លោកតា អៀង បានប្រយុទ្ធជាមួយខ្លាមួយក្បាល និង បានសម្លាប់សត្វខ្លាព្រមទាំងទុកស្បែកខ្លានោះ ឲ្យកូនចៅមើលតៗនៅជំនាន់ក្រោយផង ។ ខ្ញុំធ្លាប់បានឃើញស្បែកខ្លាធំមួយផ្ទាំងដោយផ្ទាល់ភ្នែក ដែលព្រះគ្រូ អៀង ប៊ុន ជាឪពុកធំ

ខ្ញុំ លោកថែរក្សានៅក្នុងកុដិរបស់លោក នៅក្នុងវត្តសារវន្តតេជោក្រុងភ្នំពេញនាឆ្នាំ ១៩៦០ ។ សូមបញ្ជាក់ថាជីតាខ្ញុំក៏បានហាមប្រាម កូនចៅក្រោយៗមកមិនឲ្យហាត់រៀនវិជ្ជាគុននិយមទៀតឡើយ ដោយប្រហែលជាគាត់យល់ឃើញដូចលោកឪពុកមាមេឃុំរបស់គាត់ដែរ ។

ដោយសារវិជ្ជាគុននិយមនេះ ទើបជីតារបស់ខ្ញុំបានចូលបម្រើព្រះមហាក្សត្រក្នុងព្រះបរមរាជវាំងជាមហាតលិកមួយរយៈ ក្នុងរជ្ជកាលព្រះបាទ នរោត្តម[14] ។ ក្រោយមកជីតាខ្ញុំបានមករស់នៅក្នុងភូមិមេសប្រចាន់ ។ គាត់ជាមេក្រុមទូកងដែលអង្គុយក្បាលទូក លើកច្រវាគ្រវីគ្រវាត់ ដើម្បីអ្នកអុំៗទូកស្មើចង្វាក់គ្នាឲ្យទូកមានល្បឿនលឿន ឬ យឺត ។ ក្រោយមកលោកតា អៀង បានក្លាយជាអាចារ្យប្រចាំវត្តមេសប្រចាន់ រហូតដល់ពេលលោកតាលាចាកលោកទៅក្នុងជន្មាយុប្រហែល ៧០ ឆ្នាំក្នុងឆ្នាំ ១៩៣៩ ។

ឪពុកម្តាយខ្ញុំមានកូន ១១ នាក់គឺ ប្រុស ៩ នាក់ និងស្រី ២ នាក់ ។ ខ្ញុំជាកូនទី ៣ ។ យើងទាំងអស់គ្នាសុទ្ធតែបានត្រូវបីបាច់ថែរក្សាតាមបែបប្រពៃណីរបស់អ្នកស្រុកដែលគេគោរពតៗគ្នារៀងមក ។ ខ្ញុំជាកូនដែលកើត ក្រោយពីចាប់កំណើតក្នុងផ្ទៃម្តាយអស់រយៈពេលតែ ៧ ខែទេ ។ គេអាចហៅថាកូនមិនគ្រប់ខែក៏បាន ។ នៅស្រុកយើង កូនកើត ៧ ខែគេថាមិនគ្រប់ទឹកអាចមានបញ្ហាមិនដូចពួកកូនកើតគ្រប់ខែទេ ។ រាល់ៗដងនៅពេលកើតកូន ម្តាយខ្ញុំតែងហៅរកយាយម៉ប ឬ ឆ្មបប្រចាំភូមិឈ្មោះ យាយកា ។

---

[14] នេះជាការដំណាលប្រាប់គ្នាតៗមក ដោយពួកយើងពុំមានឯកសារច្បាស់លាស់ឡើយ ។

# ការឆ្លងទន្លេនៅភូមិស្នាយពល

ការកើតកូន ខ្មែរយើងតែងហៅថាឆ្លងទន្លេ ព្រោះគេប្រដូចឧបសគ្គនៃការកើតកូន ទៅនឹងឧបសគ្គដែលអាចកើតឡើងក្នុងការហែលទឹក ឬ ជិះទូកឆ្លងទន្លេដែរគឺ បើឆ្លងមិនរួច ឬ មិនដល់ច្រាំងអាចត្រូវលង់ទឹកស្លាប់ ។ ការឆ្លងទន្លេក៏ដូច្នោះដែរ ទាំងកូនទាំងម្តាយ អាចទទួលគ្រោះថ្នាក់ដល់ជីវិត ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ នៅក្នុងភូមិស្នាយពល មានមន្ត្រីសុខាភិបាលតែម្នាក់គត់មានឋានៈត្រឹមគិលានុប្បដ្ឋាកគ្មានធ្មបនៅប្រចាំទេ[15] ។ អ្នកស្រុកភាគច្រើននៅពេលមាន ជម្ងឺតែងទៅរកគ្រូបូរាណប្រើថ្នាំខ្មែរជាជាងទៅរកគ្រូពេទ្យ ។ នៅពេលស្ត្រីកំពុងឆ្លងទន្លេគឺទារកកំពុងចេញពីផ្ទៃម្តាយ មនុស្សប្រុសៗ គេមិនអនុញ្ញាតឲ្យនៅក្នុងបន្ទប់ជាមួយឡើយ ។ បុរសដែលក្លាយជាឪពុកត្រូវរៀបចំគ្រែ ចង្ក្រាន និង ធ្យូងនៅទីជាប់ដោយឡែក ព្រោះនៅពេលដែលទារកចេញមកហើយ ស្ត្រីជាម្តាយត្រូវមកសម្រាកអាំងភ្លើងយកកម្តៅ អស់រយៈពេលបីថ្ងៃទើបឈប់ ។ នៅពេលប្រពន្ធសម្រាកនៅលើគ្រែ បុរសជាប្តី ត្រូវថែទាំមើលភ្លើងធ្យូង ភ្លើងក្នុងចង្ក្រានកុំឲ្យរលត់ ។ ការនេះ ជាការទទួលខុសត្រូវរបស់បុរសជាស្វាមីដែលមិនត្រូវខ្វះបានឡើយ ព្រោះនៅពេលភរិយាឆ្លងទន្លេនេះហើយ ដែលប្តីត្រូវបញ្ជាក់ពីសេចក្តីស្រឡាញ់ចំពោះប្រពន្ធ ឪពុកចំពោះកូន ដែលទើបនឹងកើត និង ចំពោះគ្រួសារទាំងមូលផង ។

នៅពេលឆ្លងទន្លេនេះ យាយម៉បនឹងបំពេញភារកិច្ចរបស់គាត់ដូចជា៖ ផ្សំថ្នាំលាយម្សៅ ឬ លាយរមៀតជាដើម ។ ម្តាយខ្ញុំ គាត់តែងពិសាស្រារ៉ូម (Rhum) ជំនួសស្រាថ្នាំនៅពេលឆ្លងទន្លេម្តងៗ ។ បីថ្ងៃក្រោយមក គេអាចរើចង្ក្រានពីក្រោម

[15] Cf. Sorn Samnang, L’évolution de la société cambodgienne entre les deux guerres mondiales (1919-1939), op.cit, p. 396-399.

គ្រែចេញ ដែលខ្មែរយើងហៅថាទម្លាក់ចង្ក្រាន ។ ម្ដាយត្រូវនៅបន្តសម្រាកលើគ្រែនេះតទៅទៀត មិនមានកំណត់ពេលឡើយ រហូតទាល់តែមានកម្លាំងពលំគ្រប់គ្រាន់ ។ ក្នុងរយៈពេលនេះ គេត្រូវប្រយ័ត្នប្រយែងយ៉ាងខ្លាំង ព្រោះសសៃនៅខ្ចីអាចឲ្យទាស់ នាំមកនូវជម្ងឺផ្សេងៗ ។

តាមទម្លាប់ខ្មែរយើង កូនកើតមកភ្លាម គេមិនទាន់ប្រញាប់ប្រញាល់ដាក់ឈ្មោះឲ្យកូននោះដូចនៅលោកខាងលិចនោះទេ ។ ប្រហែលជាដូនតាយើងយល់ឃើញថាត្រូវរង់ចាំមើលបន្តិចសិន ព្រោះអត្រាទារកស្លាប់ភ្លាមៗ ឬ ក្នុងអាយុពីមួយអាទិត្យទៅមួយខែ មានកម្រិតខ្ពស់ពេក ទើបគេមិនប្រញាប់រកឈ្មោះដាក់ឲ្យកូននៅពេលភ្លាមៗនោះ ។ ឪពុកខ្លះរង់ចាំពិភាក្សាជាមួយព្រះសង្ឃ លោកតាអាចារ្យ ឬ មេស្រុក មេភូមិ ដើម្បីរកឈ្មោះដាក់ឲ្យកូនឲ្យបានសមរម្យ ។ ការចុះសំបុត្រកំណើតរបស់ទារក ក៏មានលក្ខណៈដូចគ្នានេះដែរគឺ មិនប្រញាប់ប្រញាល់ប៉ុន្មានឡើយ ។ យូរៗទៅ ការចុះសំបុត្រកំណើត ក៏ស្រេចតែលើមន្ត្រីអត្រានុកូលដ្ឋានជាអ្នកសម្រេចថ្ងៃណា ខែណា ដែលសមស្រប ។ ក៏ប៉ុន្តែ ឪពុកម្ដាយភាគច្រើន តែងចាំថ្ងៃខែកំណើតរបស់កូន ទៅតាមប្រតិទិនច័ន្ទគតិគឺ គេរាប់ឆ្នាំតាមឈ្មោះសត្វទាំង១២ និង តាមខែដែលយើងហៅថាខែខ្មែរ ដោយមានខ្នើត និង រនោចផង ។ ព្រោះទាំងនេះមានសារសំខាន់ណាស់ សម្រាប់ធ្វើការទស្សន៍ទាយតាមក្បួនហោរាសាស្ត្រអំពីជោគវាសនាអនាគតរបស់កូនម្នាក់ៗ ។

ចំពោះរូបខ្ញុំអ្វីៗដែលមានចុះក្នុងបញ្ជីជាតិរបស់ខ្ញុំ ក៏ខុសស្រឡះពីអ្វីៗដែលឪពុកម្ដាយខ្ញុំបាននិយាយប្រាប់ផ្ទាល់មាត់តៗមក ។ ជាធម្មតាឪពុកម្ដាយខ្ញុំ តាំងពីពួកយើងជាកូននៅតូចៗ តែងតែបង្រៀនឲ្យយើងស្គាល់ថ្ងៃខែ ឆ្នាំកំណើតមិនឲ្យភ្លេចឡើយ ។ ជារឿយៗ គាត់តែងសួរកូនឈ្មោះអ្វី? កើតឆ្នាំអ្វី? ខែអ្វី? ថ្ងៃអ្វី? ខ្ញុំកើតថ្ងៃអង្គារ ខែអស្សុជ ឆ្នាំខាល បើគិតឲ្យត្រូវពិតប្រាកដគឺ ថ្ងៃអង្គារទី ២៤ ខែ

តុលា ឆ្នាំ ១៩៥០ ។ ចំណែកនៅក្នុងបញ្ជីជាតិរបស់ខ្ញុំ ថ្ងៃខែកំណើតគឺ ថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ១៩៥០ ឯនោះទេ ។

តាមទម្លាប់ ពួកយើងមិនដែលប្រារព្ធពិធីបុណ្យខួបកំណើតទេ ក៏ប៉ុន្តែ ឪពុកម្តាយខ្ញុំច្រើនរៀបចំពិធីសូត្រមន្តជាច្រើនដងក្នុងមួយឆ្នាំៗ ។ ឪពុកខ្ញុំឧស្សាហ៍ អញ្ជើញហោរាឲ្យមកទស្សន៍ទាយ មើលជោគជតារាសីជាញឹកញាប់ ។ ហោររបស់ ឪពុកខ្ញុំឈ្មោះ តាឃី នៅភូមិព្រៃញ្ញៅ ។ តាឃី តែងតែគន់គូរវាយលេខអត្ថៈ តើរាសី របស់គ្រួសារយើងឡើង ឬ ចុះ តើពេលណាដែលយើងត្រូវនិមន្តព្រះសង្ឃមកសូត្រ មន្តស្រោចទឹក លើករាសី ឬ រំដោះគ្រោះ ។ តាឃី បានក្លាយទៅជាមនុស្សទុកចិត្ត របស់គ្រួសារយើង ហើយឪពុកម្តាយខ្ញុំក៏មានជំនឿលើគាត់យ៉ាងមុតមាំ ។ តាមការ ណែនាំរបស់គាត់ ឪពុកខ្ញុំតែងនិមន្តលោកតាវត្តរកាមកសូត្រមន្ត និង ស្រោចទឹក រាល់ៗដង ជាទម្លាប់រៀងៗមក ។

## កុមារភាព បងប្អូន និង កិច្ចការរបស់ឪពុកខ្ញុំ

ខ្ញុំដឹងក្តីឡើងក្រោមការចិញ្ចឹមបីបាច់ថែរក្សារបស់ឪពុកម្តាយខ្ញុំ ។ ខ្ញុំមានបង ២ នាក់ទៀត បងបង្អស់ឈ្មោះ ឈឿន ហៅក្រៅថាបង "នាង" និង បងបន្ទាប់ឈ្មោះ ស៊ីនឿន ហៅបង "ផាត" ។ នៅក្នុងផ្ទះរបស់យើងៗនៅជាមួយជីដូនខ្ញុំគឺ លោក យាយ អ៊ុង គូ និង ម្តាយមីងខ្ញុំគឺ អ្នកមីងសាម៉ីឌី ។ ខ្ញុំមិនបានស្គាល់លោកយាយ ហ៊ូ ឱ ខាងឪពុកខ្ញុំទេ ដោយហេតុថាលោកយាយបានស្លាប់ជាយូរឆ្នាំទៅហើយ ។ ឪពុកម្តាយខ្ញុំមិនមានអ្នកបររទេះ ឬ អ្នកបម្រើធ្វេងស្តាំដូចជីតាខ្ញុំទេ ។ ម្តាយខ្ញុំជាប់ រវល់ការងារមេផ្ទះ ធ្វើម្ហូបអាហារ និង ថែទាំកូនចៅ ដោយមានជំនួយការពីបងជីដូន មួយខ្ញុំខ្លះ ដែលត្រូវជាក្មួយរបស់ឪពុកខ្ញុំ ។ កាលខ្ញុំនៅតូចៗនៅឡើយ បងស្រីដែល

នៅជួយមើលថែទាំខ្ញុំឈ្មោះ បងជ្រូក ។ បងជ្រូក មកស្នាក់នៅជាមួយពួកយើង ដើម្បីរៀនបញ្ចប់ថ្នាក់បឋមសិក្សា យកសញ្ញាប័ត្រទៅប្រឡងចូលធ្វើមន្ត្រីរាជការ ។ នៅពេលចេញពីសាលា បងជ្រូកតែងជួយធ្វើការម្តាយខ្ញុំ មើលថែទាំខ្ញុំ នាំខ្ញុំដើរលេង ផង និង ច្រៀងបំពេរលួងកុំឲ្យខ្ញុំយំផង ។ ដោយសារខ្ញុំនៅតូចពេក កាលពេលនោះ ខ្ញុំពុំមានចាំទុកនូវអនុស្សាវរីយ៍ណាមួយជាមួយបងជ្រូកទេ ។ ក្រោយមកបងជ្រូក បានប្រឡងជាប់ជាធ្មបរដ្ឋ ។ ខ្ញុំឮថានៅសម័យសង្គមបងជ្រូក បានប្តីជាសហគ្រិន ហើយមានជីវភាពធូរធារ រហូតមានផ្ទះថ្មមួយល្វែងធំ ស្ថិតនៅតាមមហាវិថីម៉ៅសេទុងត្រង់មុំក្បែរផ្សារដើមគបច្ចុប្បន្ន ។ បងជ្រូក ប្រហែលត្រូវបាត់បង់ជីវិតក្នុងសម័យប៉ុល ពត ព្រោះរហូតដល់សព្វថ្ងៃនេះ ខ្ញុំមិនដែលបានទទួលដំណឹងអ្វីពីគាត់សោះ ឡើយ ។

ឪពុកខ្ញុំជាប់រវល់បំពេញការងារប្រចាំការិយាល័យរបស់គាត់នៅឯផ្ទះផង និង នៅទីរួមខេត្តព្រៃវែង ដើម្បីចូលរួមកាត់ក្តីនៅសាលាដំបូងផង ។ ដូច្នេះ ក្នុងមួយខែៗ ឪពុកខ្ញុំមិនសូវនៅផ្ទះទេ ។ កាលសម័យនោះ ខេត្តព្រៃវែងចែកជា ១០ ស្រុក ក្នុង ១០ ស្រុកនោះ មានអាជ្ញាសាលាតែ ៣ នាក់ប៉ុណ្ណោះ ។ ឪពុកខ្ញុំត្រូវទទួលចាត់ការ ៣ ស្រុកគឺ៖ ស្រុកពារាំង ស្រុកស៊ីធរកណ្តាល និង ស្រុកកញ្ច្រៀច ។ មុខងារអាជ្ញាសាលា មិនមានបៀវត្សប្រចាំខែទេ តែទទួលកម្រៃក្នុងការសម្រេចសាលក្រម ឬ ប្រគល់ដីកាកោះ ។ ក្នុងសម័យនោះ អ្នកស្រុកផ្តើមធ្វើដំណើរតាមទោចក្រយានយន្តជាបណ្តើរៗហើយ ។ ឪពុកខ្ញុំពុំមានលទ្ធភាពទិញម៉ូតូថ្មីមកប្រើទេ ។ គាត់អាចទិញត្រឹមតែម៉ូតូចាស់មធ្យម ឬ ជំនំៗ ។ ដោយទំហំទឹកដីទាំង ៣ ស្រុកធំទូលាយ ការធ្វើដំណើរតាមម៉ូតូរបស់ឪពុកខ្ញុំ ក៏មានការលំបាក ព្រោះម៉ូតូចាស់នោះខូចញឹកញាប់ពេក ។ ពេលខ្លះឪពុកខ្ញុំត្រូវបណ្តើរម៉ូតូរាប់គីឡូម៉ែត្រ ទម្រាំរកជាងជួសជុលមុននឹងអាចបន្តដំណើរទៅមុខទៀតបាន ។ ខ្ញុំអាណិតឪពុកខ្ញុំណាស់ ព្រោះ

គាត់មិនដែលបានប្រើម៉ូតូថ្មីសោះ ក្នុងមួយជីវិតរបស់គាត់ ។ ម៉ូតូដែលគាត់ពេញចិត្តជាងគេគឺ ម៉ូតូបារាំងម៉ាក "ម៉ូប៊ីឡែត" (Mobilette) ។ ចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៦០ មក ម៉ូតូជប៉ុនម៉ាកហុងដា ស៊ុយហ្សុយគី ចាប់ផ្តើមលុកចូលមកដល់ភូមិយើងជាបន្តបន្ទាប់ តែឪពុកខ្ញុំនៅតែប្រើម៉ូតូម៉ូប៊ីឡែតដដែល ។

ដើម្បីជួយធ្វើការរបស់គាត់ ឪពុកខ្ញុំជួលជំនួយការម្នាក់ ដោយឲ្យប្រាក់ប្រចាំថ្ងៃ ។ ជំនួយការនោះ ចេះត្រឹមតែសរសេរ ឬ អានអក្សរខ្មែរតែប៉ុណ្ណោះ និង គ្មានមុខការអ្វីទៀតក្រៅពីប្រគល់ដីកាកោះ ឬ សេចក្តីជូនដំណឹងដល់កូនក្តី ទាំងដើមចោទទាំងចុងចម្លើយ ។ នៅពេលចេញទៅសម្រេចសាលក្រមរបស់តុលាការ ឪពុកខ្ញុំតែងសុំអន្តរាគមន៍ជានិច្ចពីអាជ្ញាធរមូលដ្ឋាន ជាពិសេស ពីសមត្ថកិច្ចតម្រួត ព្រោះការងារសម្រេចសាលក្រមនោះគឺ ត្រូវរឹបអូសទ្រព្យសម្បត្តិ ផ្ទះសម្បែង ឬ គោក្របីរបស់អ្នកចាញ់ យកទៅឲ្យអ្នកឈ្នះ ឬ យកទៅលក់ឡាយឡុងយកប្រាក់ទៅឲ្យអ្នកឈ្នះតាមសេចក្តីសំរេចរបស់តុលាការ ។ ការងារបែបនេះអាចមានគ្រោះថ្នាក់ណាស់ ព្រោះអ្នកចាញ់អាចមិនព្រមឲ្យរឹបអូស ហើយក៏អាចតដៃតាមអំពើហឹង្សាក៏មាន ។ ដោយសារទំនាក់ទំនងជាប់ជានិច្ចជាមួយអាជ្ញាធរមូលដ្ឋាន ជាពិសេស ជាមួយចៅហ្វាយស្រុក ឪពុកខ្ញុំក៏ក្លាយជាមន្ត្រីមានមុខមានមាត់ប្រចាំស្រុកផងដែរ ។

នៅឯផ្ទះ ក្នុងការិយាល័យរបស់គាត់ ឪពុកខ្ញុំធ្វើការផ្តល់យោបល់ខាងផ្លូវច្បាប់ដូចមេធាវីដែរ ។ ជួនកាលគាត់ជួយធ្វើពាក្យបណ្តឹងដល់គូក្តីដែលមានជម្លោះត្រូវឡើងតុលាការ ។ពាក្យមួយច្បាប់តម្លៃ ១០០ រៀល ឬ ប្រហែល ៣ ដុល្លារស.រ.អា ។ ឪពុកខ្ញុំតែងទទួលភ្ញៀវនៅក្នុងបន្ទប់ធំក្នុងផ្ទះ ។ នៅខាងក្រោយតុធំដែលយើងនាំគ្នាហៅថាសាឡុង មានកញ្ចក់ឆ្លុះមុខយ៉ាងធំ ដែលមានក្របធ្វើពីឈើឆ្លាក់ក្បាច់យ៉ាងល្អប្រណិត អមដោយរូបក្បាលទន្សោងពីរដែលមានស្នែងវែង ព្យួរជាប់ខាងលើខ្ពស់ផុតក្បាលមនុស្សចាស់ ។ ខេត្តព្រៃវែងសម័យនោះ ជាខេត្តដែលល្បីថា

មានក្តីក្តាំច្រើន ។ អតិថិជនរបស់ឪពុកខ្ញុំ ភាគច្រើនជាអ្នកស្រែចម្ការ ។ ពួកគាត់ជិះកង់កាត់ពីតំបន់នានានៃស្រុកទាំង ៣ មករកឪពុកខ្ញុំ ដើម្បីឲ្យជួយសម្រេចសាលក្រមតុលាការដែលសម្រេចឲ្យឈ្នះ ឬ មកពិភាក្សាច្បាប់ដើម្បីធ្វើពាក្យប្តឹង ឬ រកវិធីការពារខ្លួន ចំពោះពាក្យបណ្តឹងរបស់អ្នកដទៃជាដើម ។

ភាគច្រើន នៅពេលធ្វើដំណើរតាមរទេះកង់ អ្នកស្រុកទាំងនោះ ស្លៀកតែក្រមាប៉ុណ្ណោះទេ ឯខោដែលជាទូទៅជាខោឡាញ់ ពួកគាត់ចងនៅនឹងដែកង់បង្ការកុំឲ្យទទឹក ឬ ប្រឡាក់ នៅពេលឆ្លងកាត់ទឹក ភក់ ដីហុយតាមផ្លូវជាដើម ។ ពេលមកដល់មុខផ្ទះខ្ញុំ ពួកគាត់ផ្អែកកង់ទល់នឹងទ្វាររបង រួចរលាស់ខោឡាញ់ ផ្លាស់ក្រមា ស្លៀកខោឡាញ់នោះ និង សម្អាតរាងកាយឲ្យបានសមរម្យមុននឹងចូលមកជួបឪពុកខ្ញុំ ។ នេះជាសុជីវធម៌ ឬ ការគោរពដែលអ្នកស្រែតូចតាចសម្តែងឡើង ចំពោះមន្ត្រីរាជការដែលពួកគាត់ចាត់ទុកជាអ្នកធំ ។ ចំពោះអ្នកធំ អ្នកស្រុកប្រើពាក្យ ព្រះតេជគុណ និង ពាក្យខ្ញុំបាទ ឬ បាទទានជាដើម ។ល។

នៅពេលទំនេរពីការងារ នៅផ្ទះ ឪពុកខ្ញុំដាំដំណាំដូចជា ដូង ស្វាយ ខ្នុរ ជាដើម ។ ពួកយើងមិនមានទឹកម៉ាស៊ីនស្អាតសម្រាប់ទទួលទាន និង ប្រើប្រាស់ស្រោចដំណាំទេ ។ យើងប្រើទឹកស្រះដែលស្ថិតប្រមាណ ៣០ ម៉ែត្រពីផ្ទះ។ ក្រៅពីស្រះ យើងប្រើពាងធំៗរក្សាទុកទឹកភ្លៀងសម្រាប់ទទួលទាន ។ នៅពេលអស់ទឹកភ្លៀង ឪពុកម្តាយខ្ញុំជួលកម្មករឲ្យរែកទឹកពីអណ្តូងផ្ទះអ្នកជិតខាងចម្ងាយប្រមាណ ១០០ ម៉ែត្រមកប្រើប្រាស់ ។ ក្រោយមកខ្ញុំដឹងថាពួកកម្មករដែលយើងហៅថាគូលីមិនចង់មកស៊ីឈ្នួលរែកទឹកឲ្យពួកយើងទេ ដោយអ្នកទាំងនោះខ្លាចគេយល់ច្រឡំថាពួកគាត់ជាអ្នកទោស ។ ព្រោះកាលសម័យជីតាខ្ញុំ គាត់ច្រើនប្រើអ្នកទោសឲ្យជំរះស្មៅ ឬ រែកទឹកដាក់ពាងជាញឹកញាប់ ។

# ថ្ងៃចូលរៀនលើកដំបូង និង តម្លៃគ្រូ

កាលខ្ញុំអាយុបាន ៦ ឆ្នាំ ខ្ញុំប្រើល្បិចដើម្បីឲ្យឆាប់បានទៅរៀនមុនពេលគ្រប់អាយុ ។ ក្នុងសម័យនោះ ពុំទាន់មានថ្នាក់មត្តេយ្យនៅឡើយទេ ។ កូនក្មេងទាល់តែអាយុ ៧ ឆ្នាំ ទើបឪពុកម្ដាយឲ្យទៅរៀន ។ នៅពេលចូលរៀនលើកដំបូងម្ដងៗ កុមារខ្លះ ខ្លាចសាលា យំស្រែកមិនចង់ចូលរៀន ។ ឪពុកម្ដាយខ្ញុំ ប្រគល់ភារៈឲ្យម្ដាយមីងខ្ញុំគឺ អ្នកមីងសាម៉ីឌី ជាអ្នកសម្រេចតើពេលណាខ្ញុំអាចចូលរៀនបាន ព្រោះខ្ញុំចេះតែទារទៅសាលារៀន ។ កាលនោះ អ្នកមីងសាម៉ីឌី ជាអ្នកគ្រូ បង្រៀនថ្នាក់ឧត្តមដ្ឋាន[16] នៅសាលាបឋមសិក្សាស្នាយពល ។ អ្នកមីងជាអ្នកគ្រូក្រមុំដែលមានរូបសម្ផស្សស្អាតជាងគេនៅក្នុងភូមិ ។ តាមពិត ឪពុកម្ដាយខ្ញុំចង់ឲ្យខ្ញុំទៅរៀនដែរ តែចង់ឲ្យខ្ញុំរង់ចាំដល់អាយុគ្រប់ ៧ ឆ្នាំសិន ។

ថ្ងៃមួយ នៅពេលម្ដាយមីងខ្ញុំកំពុងអង្គុយបោកខោអាវ ខ្ញុំរត់ទៅជិតគាត់ហើយស្រែកថា "ហេ ហេ អ្នកមីងឥឡូវខ្ញុំលូកដៃដល់ត្រចៀកហើយ" ។ អ្នកមីងអស់សំណើច ព្រោះតាមធម្មតានៅជំនាន់នោះ ក្មេងៗអាចចាត់ទុកថាធំល្មម អាចទៅរៀនបាន នៅពេលដែលពួកគេអាចលើកដៃស្ដាំដាក់ពីលើក្បាល ហើយលូកទៅដល់ត្រចៀកខាងឆ្វេងបាន ។ ក៏ប៉ុន្តែ ខ្ញុំមិនធ្វើយ៉ាងដូច្នោះទេ ខ្ញុំលូកដៃស្ដាំពីក្រោយក្បាលទៅប៉ះត្រចៀកឆ្វេងតែម្ដង ដោយមិនដាក់ដៃលើក្បាលដូចអ្នកឯទៀតទេ ។ ម្ដាយមីងខ្ញុំ ឲ្យខ្ញុំធ្វើកាយវិការនេះម្ដងទៀត ហើយនៅទីបំផុតគាត់សន្យាថា នាំខ្ញុំទៅសាលារៀននៅព្រឹកថ្ងៃស្អែក ។ ព្រឹកឡើង អ្នកមីងឲ្យខ្ញុំឡើងជិះកង់ នៅខាងក្រោយហើយគាត់ក៏ឱបយកខ្ញុំទៅរៀន ។ ខ្ញុំមានក្ដីរំភើបជាអនេក ដោយបានទៅរៀនផង

---

[16] ថ្នាក់ឧត្តមដ្ឋាន ជាថ្នាក់បញ្ចប់បឋមសិក្សា និង ត្រូវប្រឡងចូលរៀនអនុវិទ្យាល័យ ។

និង បានជិះកង់ជាមួយអ្នកគ្រូក្រមុំ ដែលជាបវរកញ្ញាមួយរូបប្រចាំភូមិរបស់យើងផង ។

ខ្ញុំមានការសប្បាយរីករាយជាខ្លាំង ក្នុងការសិក្សារបស់ខ្ញុំនៅសាលាបឋមសិក្សាស្នាយពល ។ នៅពេលយើងរៀនដល់ថ្នាក់មធ្យមដ្ឋានទី១(ថ្នាក់ទី៤ថ្មី) យើងចាប់រៀនភាសាបារាំង ។ នៅពេលចូលរៀនអនុវិទ្យាល័យ មុខវិជ្ជាទាំងអស់លើកលែងតែមុខវិជ្ជាខ្មែរចេញ សុទ្ធតែជាភាសាបារាំង ។ ចេះភាសាបារាំង គេចាត់ទុកជាអ្នកចេះដឹង និង ជាបញ្ញវន្ត ។ ខ្មែរយើងមួយចំនួនច្រើននិយាយខ្មែរលាយបារាំង ដើម្បីបង្ហាញថា ជាអ្នកចេះដឹង ។ គួរកត់សម្គាល់ថានៅជំនាន់នោះ ប្រពៃណីខ្មែរយើងឲ្យតម្លៃខ្លាំងណាស់ដល់លោកគ្រូអ្នកគ្រូ ។ កូនសិស្សមានការគោរពកោតខ្លាចគ្រូជាទីបំផុត ។ នៅក្នុងសង្គម គ្រូត្រូវបានចាត់ទុកជាឪពុកម្តាយទីពីរ បន្ទាប់ពីឪពុកម្តាយបង្កើត ។ តាមឋានានុក្រមនៃការគោរព គេគោរពព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មាតា បិតា បន្ទាប់មក គេគោរពគ្រូបាធ្យាយ ។ សូម្បីតែក្នុងសិល្បៈប្រពៃណីមួយចំនួន ក៏មានការគោរពគ្រូមុននឹងសម្តែងដែរ ។ ដោយសារប្រពៃណីគោរពគ្រូយ៉ាងនេះ ធម្មតាការងាររបស់អ្នកគ្រូ លោកគ្រូ មិនមានការលំបាកឡើយ ។ កូនសិស្សខ្លាចគ្រូ គោរពគ្រូ និង ស្តាប់គ្រូខ្លាំងណាស់ ។ ក៏ប៉ុន្តែនៅមានលោកគ្រូអ្នកគ្រូខ្លះ ប្រើអំពើហឹង្សា លើសិស្សទៀតផង ។ ក្នុងថ្នាក់រៀនខ្លះ លោកគ្រូកាចត្រៀមរំពាត់ផ្តៅពីរ ឬ បីដើម ។ លោកគ្រូដែលកាចខ្លាំង ប្រើជន្ទល់បង្អួច វាយលើសិស្សណាដែលខ្ជិលច្រអូសមិន ចេះមេរៀន ឬ មានអាកប្បកិរិយាមិនគប្បី ។ តែទោះបីជាលោកគ្រូ អ្នកគ្រូកាចសម្បើមយ៉ាងណាក៏ដោយ ក៏កូនសិស្សនៅតែដឹងគុណលោកគ្រូ អ្នកគ្រូ អស់មួយជីវិត ។

មួយឆ្នាំក្រោយមក ម្តាយមីងរបស់ខ្ញុំ ត្រូវរៀបការជាមួយមន្ត្រីគយម្នាក់ឈ្មោះ អ៊ុក ថន ដែលមានស្រុកកំណើតនៅភូមិស្នាយពលក្រោម ។ ខ្ញុំក៏មិនបាន

ដឹងថាអ្នកមីង និង លោកពូមានទំនាក់ទំនងគ្នាតាំងពីពេលណា និង យ៉ាងដូចម្ដេចទេ ព្រោះម្នាក់នៅបង្រៀនឯស្នាយពល និង ម្នាក់ទៀតកំពុងបំពេញភារកិច្ចនៅឯទីក្រុងឯណោះ ។ បន្ទាប់ពីរៀបការភ្លាមមក ម្ដាយមីងខ្ញុំបានរើទៅនៅជាមួយស្វាមីរបស់គាត់ឯក្រុងភ្នំពេញ ។

ចាប់ពីពេលដែលឪពុកម្ដាយខ្ញុំរៀបអាពាហ៍ពិពាហ៍មក ប្រពៃណីរបស់អ្នកស្រុកយើង មានការប្រែប្រួលច្រើន ។ ឥឡូវ គេមិនចាំបាច់ឲ្យកូនកម្លោះមកនៅបំរើគ្រួសារខាងស្រីជាមុននោះទៀតទេ ។ បើត្រូវរ៉ូវគ្នា គេអាចរៀបចំពិធីអាពាហ៍ពិពាហ៍បាន ។ ក៏ប៉ុន្តែ ជាការចាំបាច់គេត្រូវរកគ្រូហោរាគន់គូរ ត្រួតពិនិត្យ ខែ ឆ្នាំ តើបើបានគ្នាជាគូរស្រករអាចល្អ ឬ អាក្រក់? ពិសេសទៅទៀត គេរកលោកអាចារ្យជ្រើសរើសពេលវេលាសម្រាប់រៀបមង្គលការ ដើម្បីឲ្យគូស្វាមី មានសិរីសួស្ដី និង ជោគជ័យក្នុងជីវិតទៅអនាគត ។ ទោះបីប្រពៃណីរបស់យើង មានការវិវឌ្ឍខ្លះក៏ដោយ ក៏គេនៅរៀបចំពិធីអាពាហ៍ពិពាហ៍ក្នុងរយៈពេលបីថ្ងៃ បីយប់ដូចពីមុនដែរ ។

ប៉ុន្មានថ្ងៃមុនពេលពិធីមង្គលការរបស់ម្ដាយមីងខ្ញុំចាប់ផ្ដើម ម្នាក់ៗរវល់ញាប់ដៃ ។ ប្រុសៗនាំគ្នាសង់រោង ឯស្ត្រីៗនាំគ្នាវេចនំ មាននំអន្សម នំគម នំបត់ តាមទម្លាប់ ។ គេសង់រោងធំសម្រាប់ពិធីជប់លៀង និង រោងតូចមួយទៀតជារោងសម្រាប់ទទួលកូនកម្លោះ ដែលត្រូវស្នាក់នៅក្នុងរយៈពេលនៃពិធីទាំងមូល និងដែលជាទីកន្លែងសម្រាប់អ្នកភ្លេង និង អ្នកចំរៀង សម្ដែងសិល្បៈប្រពៃណីផង ។ នៅខាងក្រោយផ្ទះ ពួកកម្មករនាំគ្នាជីករណ្ដៅ ធ្វើចង្ក្រានខ្ទះធ្នោត ទុកសម្រាប់ចំអិនម្ហូបអាហារ ដែលគេត្រូវការផ្គត់ផ្គង់ដល់ភ្ញៀវក្នុងរយៈពេលបីថ្ងៃ បីយប់នៃពិធីរួមទាំងពិធីជប់លៀងធំនៅថ្ងៃបង្ហើយផង ។ ឃើញគេធ្វើរោងបាយ និង ជីករណ្ដៅយ៉ាងនេះ កាលនោះខ្ញុំមានអាយុទើបតែបាន ៧ ឆ្នាំ ខ្ញុំនឹកឆ្ងល់ក្នុងចិត្តថា ហេតុដូចម្ដេចបានជាគ្មានអ្នកណាបើកហាងដែលមានបន្ទប់ធំទូលាយ មានតុកៅអីស្រេច ត្រៀមជួល

ក្នុងពេលមង្គលការ ដោយមិនចាំបាច់ធ្វើរោង ឬ ដីកដីធ្វើអ្វី?កាលនោះ ខ្ញុំអត់ដឹងថា នៅទីក្រុងភ្នំពេញ គេមានសណ្ឋាគារ ឬ ភោជនីយដ្ឋានធំៗ ដែលគេអាចជួលកន្លែង សម្រាប់រៀបចំពិធីផ្សេងៗរួចទៅហើយ ។

## សកម្មភាពក្រៅថ្នាក់រៀន

ម្តាយមីងយើងបានឃ្លាតពីយើងទៅ តែផ្ទះយើងក៏ទទួលបានអ្នកចំណូល ថ្មីៗទៀតដែរ ។ គ្រួសារយើង ចេះតែមានចំនួនសមាជិកកើនឡើងៗពីមួយឆ្នាំទៅ មួយឆ្នាំ ។ មុនពេលខ្ញុំចេញទៅរៀននៅភ្នំពេញនៅឆ្នាំ ១៩៦៤ ខ្ញុំមានប្អូនស្រីពីរនាក់ គឺ វន្នី កើតឆ្នាំ ១៩៥២ ស៊ីថាន ឆ្នាំ ១៩៥៤ និង ប្អូនប្រុសបួននាក់គឺៈ វណ្ណៈ កើតឆ្នាំ ១៩៥៦ ណារើន ឆ្នាំ ១៩៥៩ វុធធៀន ឆ្នាំ ១៩៦២ និង វុធធឿន ឆ្នាំ ១៩៦៤ ។ ប្អូនប្រុសពីរនាក់ទៀតគឺ វុទ្ធា កើតនៅឆ្នាំ ១៩៦៦ និង សោភា ឆ្នាំ ១៩៧០ ។

កាលរស់នៅឯភូមិស្នាយពលនោះ ពួកយើងមានចិញ្ចឹមសត្វដូចជាៈ មាន់ ទា ឆ្កែ និង ឆ្មាផង ។ នៅឆ្នាំខ្លះ ឪពុកខ្ញុំ ចិញ្ចឹមគោ ឬ សេះ ដើម្បីយកលាមកមកធ្វើ ដី សម្រាប់ដំណាំដាំដុះរបស់គាត់ ។ នៅខាងក្រោយផ្ទះ យើងពុំមានធ្វើរបងទេ តែមានស្នាមភ្លោះ និង ព្រៃរបោះតូចៗរួមផ្សំនឹងគុម្ពឫស្សីដុះព័ទ្ធជុំជិត ។ ជាមួយ នោះ ក៏មានដើមត្នោតយ៉ាងខ្ពស់លលៃ ដុះលេចទៅលើយ៉ាងខ្ពស់ចំនួនពីរ ឬ បីដើម ទៀត ។ ពួកយើងឧស្សាហ៍ទៅរើសត្នោតទុំដែលជ្រុះមកដី ដើម្បីទុកឲ្យម្តាយយើង ធ្វើនំ (នំត្នោត) ឬ ធ្វើចាហួយជាដើម ។ នៅចុងត្នោតដែលខ្ពស់ជាងគេ មានសត្វ ក្រសារមួយគូកាច់សំបុកនៅទីនោះ ។

ព្រឹកមួយ នៅពេលខ្ញុំទៅរើសត្នោតទុំ ខ្ញុំឃើញកូនសត្វក្រសារស្រែកខ្សាវៗ ដែលនៅពីចម្ងាយយើងពុំអាចឮសម្រែកបានឡើយ ។ ខ្ញុំចូលទៅរើសផ្លែត្នោតទុំ និង យកកូនសត្វក្រសារមកចិញ្ចឹម ។ ពេលកូនក្រសារកាន់តែធំបន្តិចម្តងៗ គេក៏ក្លាយទៅជាមិត្តសំឡាញ់ជិតស្និទ្ធជាមួយសត្វឯទៀត ជាពិសេស ជាមួយសត្វឆ្កែរបស់យើង ។ រាល់ពេលខ្ញុំត្រឡប់មកពីសាលារៀនវិញ ទាំងឆ្កែ ទាំងក្រសាររត់មកទទួលខ្ញុំ ។ ឆ្កែលោតប្រតោងលិទ្ធដៃលិទ្ធជើង ឯក្រសារក៏ទទះស្លាប ស្រែកកកេកកកាក រត់មកជិត ហើយយកចំពុះមកប្រចិកដៃប្រចិកជើងខ្ញុំយ៉ាងសប្បាយរីករាយ ។ កូនសត្វក្រសាររស់នៅជាមួយពួកយើង រហូតដល់ពេលដែលគេអាចហើរដោយខ្លួនឯងបាន គេក៏ហើរទៅរស់នៅជាមួយហ្វូងក្រសារឯទៀតដោយសេរី និង ដោយសុខសាន្ត ។

ក្នុងរយៈពេលនោះ យើងក៏មានចិញ្ចឹមសត្វស្វាមួយក្បាលដែរ ។ នៅរាល់ពេលព្រឹក ជាមួយស្នូរសម្រែកសត្វជ្រូក ដែលស្រែកថ្ងូរមិនឈប់នោះ សត្វស្វាក៏ជួយដាស់យើងឲ្យភ្ញាក់ពីដំណេកទាំងពេលព្រឹកទៀបភ្លឺដែរ ។ យើងមិនបានចិញ្ចឹមសត្វស្វាទុកក្នុងទ្រុងទេគឺ យើងលែងវាឲ្យមានសេរីភាពនៅពេលថ្ងៃ ។ នៅពេលល្ងាចទើបយើងចងវាទុក ។ មុននឹងយើងបិទទ្វារផ្ទះ និង ចូលនិទ្រានៅខាងក្នុង យើងចងស្វាភ្ជាប់ជាមួយសសរបង្គោលអង្រឹងដែលយើងដាក់នៅយ៉ខាងមុខ សម្រាប់មើលទេសភាពនៅមុខផ្ទះ ។ នៅពេលជិតភ្លឺ សត្វស្វាតែងលោតពីសសរមួយ ទៅសសរមួយ អង្រន់អង្រឹងមិនឈប់ដែលយើងពិបាកនឹងទ្រាំ ។ សត្វស្វារស់នៅជាមួយសត្វឯទៀតដោយសុខស្រួលដោយគ្មានបញ្ហាអ្វីឡើយ ។ ស្វានោះចូលចិត្តប្រឡែងលេងជាមួយឆ្កែ ។

បន្ទាប់ពីពេលបាយ នៅពេលដែលចាស់ៗសម្រាន្តថ្ងៃ ស្វាសម្ងំរកចៃ ឬជួយសម្អាតរោមឆ្កែដែលនៅជិតខ្លួន ។ ថ្ងៃមួយ មេឆ្កែរបស់យើងកើតកូនប្រាំ ។ ស្វា

ស្រឡាញ់ចូលចិត្តកូនឆ្កែណាស់ ។ វាប្រឡែងលេងជាមួយ និង ថ្នាក់ថ្នមកូនឆ្កែជានិច្ច ។ ក្រោយមកប៉ុន្មានថ្ងៃ នៅពេលដែលខ្ញុំកំពុងសម្ងំអានសៀវភៅ និង ទន្ទេញមេរៀន ខ្ញុំឮសំឡេងឆ្កែព្រូសឥតឈប់ដែលធ្វើឲ្យខ្ញុំបែកអារម្មណ៍ ។ សម្លឹងតាមបង្អួចខ្ញុំឃើញឆ្កែរត់ជុំវិញដើមអំពិលដែលនៅក្បែរផ្ទះ វាព្រូសផង វាប៉ុនប៉ងឡើងដើមអំពិលផង ។ នៅពេលខ្ញុំមកដល់ ឆ្កែនៅតែព្រូស វាព្រូសឡើងលើ ដោយយកជើងកន្ត្រាងឡើងតាមគល់អំពិល ។ នៅឯលើមែកអំពិល ខ្ញុំឃើញស្វាអង្គុយយ៉ាងស្រួល ដៃវាម្ខាងកាន់កូនឆ្កែ ដៃម្ខាងទៀតរកចៃឲ្យកូនឆ្កែនោះ ។ កូនឆ្កែស្រែកបន្តិចបន្តួចហាក់ដូចជាបានទទួលការថ្នាក់ថ្នមដែលវាពេញចិត្ត ។ ទោះជាខ្ញុំខំស្រែកហៅយ៉ាងណាក៏ដោយ ក៏ស្វាពុំព្រមយកកូនឆ្កែចុះមកដីវិញដែរ ។ ពេលឮខ្ញុំហៅ ស្វាធ្វើមាត់ជីបអូចៗ ញាក់មុខញាក់មាត់តែប៉ុណ្ណោះ ។ នៅទីបំផុត ខ្ញុំក៏រត់ទៅយកចេកទុំមួយផ្លែមកគ្រវីឲ្យស្វាជាសញ្ញាថាចុះមកដីវានឹងបានរង្វាន់ ។ ស្វាក៏បីកូនឆ្កែចុះមកដីវិញយ៉ាងស្រួល ។ ប៉ុន្មានខែក្រោយមកយើងក៏យកស្វាទៅប្រគេនលោក ព្រោះយើងជឿថាស្វានោះនឹងបានទទួលសេរីភាព និង អាចរស់នៅដោយសុខសាន្តនៅក្នុងព្រៃក្បែរវត្តជាពុំខាន ។

កាលនៅវ័យកុមារខ្ញុំចូលចិត្តលេងល្បែងធ្វើគ្រូ ធ្វើជាសង្ឃ ឬ ជួនកាលធ្វើស្តេចជាដើម ។ ជាពិសេស លេងល្បែងអ្វីដែលក្មេងៗឯទៀតត្រូវគោរពកោតខ្លាច ។ ជួនកាលខ្ញុំរៀនធ្វើត្រាប់តាមសម្តេចឪ (គឺព្រះករុណាសម្តេចព្រះ នរោត្តម សីហនុ កាលព្រះអង្គនៅកាន់អំណាចជាព្រះប្រមុខរដ្ឋ) ។ ខ្ញុំនៅចាំថាសម្តេចយាងមកភូមិស្នាយពលពីរដងដែរ លើកចុងក្រោយនៅឆ្នាំ ១៩៦៣ ។ ជារៀងរាល់ថ្ងៃ យើងតែងឮតាមវិទ្យុជាតិនូវព្រះសូរសៀងរបស់ព្រះអង្គដែលទ្រង់ថ្លែងជាញឹកញាប់ ។ សម័យនោះ ពួកយើងគោរពសម្តេចឪ ដូចយើងគោរពព្រះពុទ្ធអង្គយ៉ាងដូច្នោះដែរ ។

ខ្ញុំក៏ធ្លាប់លេងល្បែងដូចជាលេងបញ្ចាំងកុនជាដើម ។ ពេលនោះ យើងគ្មាន

ភ្លើងអគ្គិសនី និង គ្មានម៉ាស៊ីនបញ្ចាំងទេ ។ ខ្ញុំយកកញ្ចក់ឆ្លុះមុខមកជិតពន្លឺភ្លើងទៀន ធ្វើឲ្យកញ្ចក់ជះពន្លឺទៀនទៅទីងងឹតខាងមុខ លេចចេញជាពន្លឺការ៉េបួនជ្រុង ឬ មូលទៅតាមរាងរបស់កញ្ចក់ ។ បើយើងកាត់ក្រដាសធ្វើជារាងសត្វអ្វីមួយ ឬ រាងមនុស្ស ដាក់លើកញ្ចក់ៗក៏បញ្ចាំងស្រមោលខ្មៅនៃរាងសត្វ ឬ រាងមនុស្សនោះនៅក្នុងពន្លឺការ៉េ ឬ មូលទៅទីងងឹត ។ ខ្ញុំអាចយោល ឬ បង្វិលរូបក្រដាសធ្វើឲ្យមានចលនាចុះឡើងជាមួយការធ្វើអត្ថាធិប្បាយកំប្លុកកំប្លែង តាមការនឹកឃើញរបស់ខ្ញុំ ។

នៅឆ្នាំដំបូងនៃទសវត្សរ៍ឆ្នាំ ១៩៦០ ភូមិយើងចាប់ផ្តើមមានអគ្គិសនីជាបណ្តើរៗហើយ ។ ថៅកែម្នាក់បានដំឡើងម៉ាស៊ីនភ្លើងដែលមានកម្លាំងមិនលើសពីម្ភៃគីឡូវ៉ាត់ ដើម្បីឲ្យអ្នកស្រុកជាវភ្លើងប្រើ ចាប់ពីម៉ោង ៥ ទៅ ៦ ព្រឹក និង ពីម៉ោង ៦ ល្ងាចទៅម៉ោង ១០ យប់ ។ អំពូលម៉ែត្រមួយប្រវែង០,៣០ម៉ែត្រ ជាវថ្លៃ ៣០ រៀល ឬ ១ ដុល្លារស.រ.អាក្នុងមួយខែ ។ ផ្ទះយើងជាវតែអំពូលបីតឹកមួយសម្រាប់ប្រើជាប្រចាំតែប៉ុណ្ណោះ ។ យើងដាក់អំពូលឲ្យខ្ពស់ផុតពីជញ្ជាំងបាំងចែកបន្ទប់ដើម្បីឲ្យពន្លឺអាចជះចូលទៅគ្រប់បន្ទប់ ព្រោះផ្ទះយើងពុំមានពិដានទេ ។ ក៏ប៉ុន្តែ ពន្លឺពុំអាចបំភ្លឺឲ្យច្បាស់នៅគ្រប់បន្ទប់ឡើយ ។ នៅពេលយប់ បើត្រូវការធ្វើកិច្ចការដែលគ្រូដាក់ឲ្យធ្វើ ខ្ញុំត្រូវមកធ្វើកិច្ចការនោះនៅការិយាល័យរបស់ឪពុកខ្ញុំ ដូច្នេះជួនកាលខ្ញុំត្រូវលង់លក់នៅក្នុងការិយាល័យនោះក៏មាន ។

ដើម្បីចៀសវាងផលវិបាកបែបនេះ ខ្ញុំក៏លបតភ្លើងដោយខ្លួនឯង ។ កាលនោះ ខ្ញុំមិនទាន់យល់ដឹងគ្រោះថ្នាក់អគ្គិសនីធក់យ៉ាងដូចម្តេចនៅឡើយទេ ។ ខ្ញុំទិញអំពូលមូលមួយគ្រាប់ពីផ្ទះចិននៅក្បែរផ្សារ ហើយក៏តខ្សែលួសធម្មតា ព្រោះមិនអាចរកខ្សែភ្លើងធម្មតាបាន ។ ខ្ញុំតអំពូលដាក់ប្រើនៅក្នុងបន្ទប់ខ្ញុំយ៉ាងស្រួល ដោយមិនចាំបាច់ចំណាយប្រាក់ជាវថ្លៃអគ្គិសនីដូចអ្នកឯទៀតឡើយ ។ អស់ជាច្រើនសប្តាហ៍ យើងសប្បាយនឹងប្រើភ្លើងបន្ថែមដោយមិនបាច់បង់ថ្លៃ ។ ក៏ប៉ុន្តែ ថ្ងៃមួយ

ជាចៃដន្យ ខ្ញុំប្រទះឃើញខ្សែលួសត្រង់តំណតពីខ្សែភ្លើងធំ មានពណ៌ក្រហមដូចរងើកភ្លើង ។ ខ្ញុំស្ទុះទៅជិតខ្សែលួសតំណក៏ឃើញកំពុងឆេះប្រវែងប្រហែល ១០ សង្ទីម៉ែត្រ ។ ខ្ញុំភ័យខ្លាំងណាស់ ព្រោះខ្ញុំខ្លាចឆេះផ្ទះ ។ ដូច្នេះ ខ្ញុំក៏យកដំបងមកវាយផ្តាច់ខ្សែលួសឲ្យដាច់ចេញពីខ្សែភ្លើងមួយរំពេច ។ ខ្សែលួសក៏លែងឆេះ តែអំពូលមូលរបស់ខ្ញុំក៏ឈប់ភ្លឺតាំងពីថ្ងៃនោះមកដែរ ។ ខ្ញុំលាក់ការសម្ងាត់នេះមិនឲ្យនរណាដឹងឮឡើយ ។ ខ្ញុំក៏លែងហ៊ានលេងល្បែងដ៏គ្រោះថ្នាក់នេះតទៅទៀត ព្រោះអាចនាំឲ្យឆេះផ្ទះដែលជាកេរដំណែលរបស់ជូនតាខ្ញុំ ។

## ការគិតគូរអំពីបញ្ហាស្រុកទេស

ជាទូទៅ នៅសម័យនោះ ភូមិយើងមិនទាន់មានចង្កៀងអគ្គិសនីបំភ្លឺជាសាធារណៈនៅឡើយទេ ។ ប៉ុន្តែ ដោយសារពន្លឺចង្កៀងអគ្គិសនីដែលជះចេញពីផ្ទះនានានៅសង្ខាងផ្លូវធំនោះ យើងក៏អាចមើលឃើញម្តងៗនូវអ្នកដំណើរថ្មើរជើង ឬអ្នកជិះកង់ ជិះម៉ូតូដែលធ្វើដំណើរហូរហែតាមផ្លូវ ។ ដោយសារមានពន្លឺចង្កៀងភ្លឺបន្តិចបន្តួចនេះ អ្នកស្រុកក៏ចូលចិត្តដើរលេងយប់ ។ នៅពីលើយ៉ខាងមុខផ្ទះជូនកាលខ្ញុំអាចឃើញភ្ញៀវចូលមកលេងដោយមិនបានត្រៀមទុក ។ ពេលណាមានគេមករក ខ្ញុំជូនដំណឹងទៅឪពុកខ្ញុំភ្លាម ។ ជាញឹកញាប់ ភ្ញៀវច្រើនមកលេងក្រោយពេលបាយល្ងាចរួច ព្រោះពួកគាត់ចង់ជជែកគ្នាពីនេះពីនោះ រហូតដល់ពេលងងុយទើបត្រឡប់ទៅផ្ទះវិញ ។ អ្នកទាំងនោះ ច្រើនរើកញែកអំពីបញ្ហានយោបាយអន្តរជាតិរាប់ទាំងសង្គ្រាមនៅកូរ៉េ ជម្លោះនៅកុងហ្គោ ជាពិសេស សង្គ្រាមនៅប្រទេសជិត

ខាងគឺ នៅប្រទេសលាវ[17] ឬ វៀតណាម និង បញ្ហាប្រណាំងប្រជែងផ្នែកបរមាណូ ។ អ្នកទាំងនោះ ក៏ធ្វើអត្ថាធិប្បាយអំពីមហាយក្សធំៗដូចជាៈ សហភាពសូវៀត ស.រ.អា បារាំង អង់គ្លេស និង ចិនជាដើម... ។ ពួកគាត់ ធ្វើអត្ថាធិប្បាយទៅលើព័ត៌មានដែលបានទទួលតាមវិទ្យុជាតិ និង ដែលមានផ្សាយមួយថ្ងៃ ៣ ដង។ ក៏ប៉ុន្តែជាទូទៅពួកគាត់ ច្រើននិយាយតាមសម្តេចឪ ដែលលោកតែងធ្វើអត្ថាធិប្បាយតាមវិទ្យុជារៀងរាល់ថ្ងៃ ។

ក្នុងសម័យនោះ សម្តេចជាព្រះប្រមុខរដ្ឋ និង ជាប្រធានចលនាសង្គមរាស្ត្រនិយម ។ សម្តេចតែងយាងទៅសួរសុខទុក្ខប្រជារាស្ត្ររបស់ព្រះអង្គ នៅទីកន្លែងជាច្រើននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយជារៀងរាល់ដង ព្រះអង្គតែងថ្លែងព្រះសុន្ទរកថាដែលគេផ្សាយតាមវិទ្យុជាច្រើនម៉ោង ក្នុងមួយថ្ងៃៗ ។ ឪពុកខ្ញុំ និង ភ្ញៀវរបស់គាត់ មិនសូវធ្វើអត្ថាធិប្បាយអំពីបញ្ហាក្នុងស្រុកទេ លើកលែងតែមានរឿងរ៉ាវណាដែលទាក់ទងដល់រដ្ឋមន្ត្រី និង មន្ត្រីធំៗដែលគាត់ស្គាល់ ។ ទាំងអស់គ្នាតែងកោតសរសើរការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចឪ ។ ខ្ញុំក៏បានរៀនសូត្រអំពីរឿងនយោបាយអន្តរជាតិ តាមរយៈការស្តាប់ចាស់ៗពិភាក្សាគ្នា នៅពេលចាក់តែជូនពួកគាត់ ។ ខ្ញុំក៏ដឹងនៅពេលក្រោយមកថា ឪពុកខ្ញុំក៏ធ្លាប់ឈរឈ្មោះបោះឆ្នោតតំណាងរាស្ត្រដែលរៀបចំឡើងជាលើកដំបូង ដោយសង្គមរាស្ត្រនិយមដែរ ប៉ុន្តែមិនបានជាប់ឆ្នោត ។

នៅរៀងរាល់សប្តាហ៍ លោកចៅហ្វាយស្រុកតែងកោះអញ្ជើញលោកមេឃុំគ្រប់ឃុំឲ្យមករួមប្រជុំនៅសាលាស្រុក ។ លោកមេឃុំមេសប្រចាន់ ជាបងប្អូនជីដូនមួយរបស់ឪពុកខ្ញុំ ។ រាល់ៗដង នៅពេលប្រជុំរួចគាត់តែងមកផ្ទះខ្ញុំ ដើម្បីរួមពិសា

[17] សម័យនោះ គេហៅថាប្រទេស លាវ ឥឡូវគេហៅថា ប្រទេសឡាវ ។

បាយថ្ងៃត្រង់ ឬ ក៏ចូលមកសំណេះសំណាលជាមួយឪពុកខ្ញុំ ។ ដំបូងគាត់ធ្វើដំណើរតាមទោចក្រយាន ក្រោយមកតាមទោចក្រយានយន្ត ហើយគាត់តែងដាក់កង់ ឬ ម៉ូតូរបស់គាត់នៅក្រោមផ្ទះ រួចឡើងជណ្តើរទៅឯលើ ដើម្បីជួបឪពុកខ្ញុំនៅការិយាល័យរបស់គាត់ ។ នៅពេលលោកមេឃុំជាប់រវល់ជជែក ឬ និយាយលេងជាមួយឪពុកខ្ញុំៗក៏រវល់ត្រួតពិនិត្យរបស់របររបស់គាត់ នៅឯក្រោម ដែលគាត់ចងជារម្ងរធំនៅលើចង្កើរកង់ ឬ ម៉ូតូរបស់គាត់ដែរ ។ រម្ងរដ៏ធំនោះគឺ ទស្សនាវដ្តីចំនួនដប់ ឬ ម្ភៃក្បាលដែលគាត់ត្រូវយកទៅផ្សព្វផ្សាយនៅតាមឃុំរបស់គាត់ ។ ខ្ញុំព្យាយាមទាញយកទស្សនាវដ្តីពីរ ឬ បីក្បាលនៅកណ្តាលរម្ងរ យកមកទុកអានខ្លួនឯង ដោយមិនឲ្យលោកមេឃុំដឹងជាមុនឡើយ ។ ឯលោកមេឃុំមិនដែលចាប់អារម្មណ៍ថាមានអ្នកលួចដកហូតទស្សនាវដ្តីរបស់គាត់ដែរទេ ព្រោះខ្ញុំចងរឹតបន្តឹងរម្ងរឯកសារនោះឲ្យណែនឡើងវិញ មិនអាចជ្រុះបានឡើយ ។

ទស្សនាវដ្តីសម័យនោះ ឈ្មោះអ្នកជាតិនិយម ដែលជាទស្សនាវដ្តីមានប្រជាប្រិយភាពណាស់ និង ដែលត្រូវបានបោះពុម្ពផ្សាយ ដោយចលនាសង្គមរាស្ត្រនិយម ។ ខ្ញុំចូលចិត្តអានអត្ថបទ និង មើលរូបភាព នៅក្នុងទស្សនាវដ្តីនោះណាស់ ព្រោះគេមានផ្សព្វផ្សាយអំពីសកម្មភាពការងាររបស់រាជរដ្ឋាភិបាល និង ព្រះឆាយាល័ក្ខណ៍របស់ព្រះមហាក្សត្រ ព្រះមហាក្សត្រីយានី សម្តេចព្រះឧបយុវរាជ ក្រោយមកសម្តេចព្រះប្រមុខរដ្ឋ និង មន្ត្រីធំៗ ។ ខ្ញុំចូលចិត្តអានព័ត៌មានអន្តរជាតិ ដែលអាចជួយខ្ញុំឲ្យយល់ដឹងនូវប្រធានបទដែលឪពុកខ្ញុំ និង ភ្ញៀវរបស់គាត់តែងជជែកគ្នាលេងនៅរាល់ៗយប់នោះ ។ ខ្ញុំចូលចិត្តមើលរូបគំនូរកំប្លុកកំប្លែង ដូចជារូបរបស់លោកប្រធានាធិបតី អៃស៊ិនហាវ័រ (Eisenhower)[18] នៃសហរដ្ឋអាមេរិក លោក

[18] Dwight David Eisenhower (October 14, 1890 – March 28, 1969) was the 34th President of the United States from 1953 until 1961. លោក អៃស៊ិនហាវ័រ ជាប្រធានាធិបតីទី ៣៤ នៃសហរដ្ឋអាមេរិក ពីឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៦១។

គ្រុតឆេវ (Khrushchev)[19] នៃសហភាពសូវៀត លោក ដឺហ្គោល (De Gaulle)[20] នៃប្រទេសបារាំងជាដើម ។ ក្នុងនោះក៏មានរូបកំប្លុកកំប្លែងរបស់សម្តេចឪ និង រូបរបស់មន្ត្រីធំៗឯទៀតមួយចំនួនដែរ ។ ដូច្នេះ ការអានទស្សនាវដ្តីនេះរាប់បានថា ជាការរៀនសូត្រមួយផ្នែកនយោបាយអន្តរជាតិរបស់ខ្ញុំ ។

## ខ្ញុំចូលចិត្តកសាងកុសល

នៅពេលខ្ញុំចូលរៀនថ្នាក់ឧត្តមដ្ឋាន ឪពុកខ្ញុំ ម្តាយខ្ញុំ បានសង្កេតឃើញថា ខ្ញុំចូលចិត្តគូរគំនូរ និង មើលសៀវភៅ ។ ខ្ញុំចូលចិត្តគូររូបសត្វ ផ្ទះ ឡាន ដើមឈើ និង ទេសភាពដោយប្រើពណ៌ទឹក ។ ក៏ប៉ុន្តែ អ្វីដែលគួរកត់សម្គាល់នោះគឺ ខ្ញុំគូរគំនូរ ព្រះពុទ្ធ ក្នុងព្រះឥរិយាបថផ្សេងៗ និង ក្នុងសកម្មភាពសំខាន់ៗរបស់ព្រះអង្គ ។ ជីដូន និង ម្តាយខ្ញុំសប្បាយចិត្ត និង ចង់ឃើញរូបគំនូរទាំងអស់នោះណាស់ ហើយ តែងលើកទឹកចិត្តខ្ញុំឲ្យគូរឲ្យបានច្រើន ។ ពួកគាត់និយាយថា អំពើទាំងនេះជាការ កសាងកុសល ដូចសាងអំពើល្អ ឬ ធ្វើបុណ្យយ៉ាងដូច្នោះដែរ ដែលអាចនាំឲ្យយើង ឡើងឋានសួគ៌បាន ។ ម្យ៉ាងទៀត ខ្ញុំក៏ចូលចិត្តអានសៀវភៅធម៌ ដែលប្រដៅប្រដៅ យើង ឲ្យប្រព្រឹត្តទៅតាមគន្លងព្រះពុទ្ធសាសនា ឬ ឲ្យយល់ដឹងអំពីវិន័យព្រះសង្ឃ

---

[19] Nikita Sergeyevich Khrushchev (April 15, 1894 – September 11, 1971) led the Soviet Union during part of the Cold War. He served as First Secretary of the Communist Party of the Soviet Union from 1953 to 1964, and as Chairman of the Council of Ministers, or Premier, from 1958 to 1964. លោក គ្រុតឆេវ ជាអ្នកដឹកនាំសហភាពសូវៀត ពីឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៦៤ ក្នុងឋានៈជាលេខាទី១នៃបក្សកុម្មុយនីស្ត ពីឆ្នាំ ១៩៥៣ ដល់ ១៩៦៤ និង ជានាយករដ្ឋមន្ត្រី ពីឆ្នាំ ១៩៥៨ ដល់ ១៩៦៤ ។

[20] Charles André Joseph Marie de Gaulle (22 November 1890 – 9 November 1970) was a French general and statesman who led the Free French Forces during World War II. He later founded the French Fifth Republic in 1958 and served as its first President from 1959 to 1969. លោក ដឺហ្គោល ជាឧត្តមសេនីយ និងរដ្ឋបុរសបារាំងដែល បានដឹកនាំកងកម្លាំងបារាំងសេរីប្រឆាំងកងទ័ពអាឡឺម៉ង់នៅសង្គ្រាមលោកលើកទី២។ លោកជាស្ថាបនិកនៃសាធារណរដ្ឋ បារាំងទី៥ និង ជាប្រធានាធិបតីទី១នៃសាធារណរដ្ឋនេះ ពីឆ្នាំ ១៩៥៩ ដល់ ១៩៦៩ ។

ដែរ ។

ថ្ងៃមួយជីដូនខ្ញុំ នាំខ្ញុំទៅលេងភូមិកំពង់ទ្រា ក្នុងឃុំមេសប្រចាន់ ។ នៅក្នុងផ្ទះ ដែលយើងសម្រាក ខ្ញុំក៏រើសយកសៀវភៅធម៌ដែលមានចំណាស់មួយក្បាលមកអាន ។ នៅវគ្គដំបូង ខ្ញុំចាប់ផ្ដើមអានព្យាង្គៗយ៉ាងច្បាស់ៗ និង មួយៗដោយមានការប្រុងប្រយ័ត្នមិនឲ្យខុសអក្ខរាវិរុទ្ធ ឬ វគ្គឃ្លាឡើយ ។ នៅពេលខ្ញុំកំពុងអាននោះ យាយៗបួនដប់នាក់ចូលមកអង្គុយបត់ជើងជុំវិញខ្ញុំ ។ យាយម្នាក់ស្ទុះទៅដុតធូបនៅចំពោះមុខខ្ញុំ ហាក់ដូចជាយល់ថាខ្ញុំកំពុងតែសូត្រធម៌ ឬ សម្ដែងធម៌ទេសនាក្នុងពិធីបុណ្យមែនទែនដូច្នោះដែរ ។ ដោយឃើញដូច្នេះ ខ្ញុំក៏មិនហ៊ានឈប់ហើយត្រូវបន្តអានរហូតដល់ចប់ ។ ជីដូនខ្ញុំក៏និយាយថា ខ្ញុំធ្វើបុណ្យបានច្រើនណាស់ ដោយសារបានអានសៀវភៅធម៌ជូនចាស់ៗស្ដាប់ ។ ខ្ញុំជក់ចិត្តជាប់នឹងព្រះពុទ្ធសាសនាស្ទើរតែចង់បែកចិត្តឈប់រៀន នៅពេលអាយុ ១៣ ឆ្នាំ ដើម្បីទៅសាងផ្នួសបួសជាសាមណេរ ។ ក៏ប៉ុន្តែ នៅទីបញ្ចប់ខ្ញុំមិនបានបួសទេ ហើយបន្តរៀនរហូតមក ។ ខ្ញុំមានចិត្តចង់ធ្វើបុណ្យតាំងពីតូច ។ នៅពេលខ្ញុំជិះកង់ ឬ ម៉ូតូ ហើយជួបមនុស្សចាស់ ឬ ព្រះសង្ឃដែលកំពុងតែដើរ ឬ និមន្តក្រោមកម្ដៅថ្ងៃ ខ្ញុំតែងតែហៅគាត់ ឬ និមន្តលោកឲ្យជិះកង់ជាមួយខ្ញុំ រួចខ្ញុំជូនដំណើរគាត់ ឬ ព្រះអង្គទៅដល់ទីដៅ ។

# ខ្ញុំចូលចិត្តអានសៀវភៅ

នៅខាងលិចផ្ទះខ្ញុំ មានផ្ទះបងប្អូនជីទួតមួយម្នាក់ ហៅផ្ទះនឹងប៉េន (បងថ្លៃ) ។ នឹងប៉េនទើបនឹងសង់ផ្ទះ ហើយប្ដូរយកមុខរបរថ្មី ។ កាលពីមុនគាត់លក់និង តំឡើង ឬ ជួសជុលទោចក្រយាន ។ នៅទសវត្សរ៍ឆ្នាំ ១៩៦០ គាត់មកប្រកប

របរជាអ្នកលក់សៀវភៅ ជាម្ចាស់បណ្ណាគារម្តងវិញ ។ នៅក្នុងបណ្ណាគារ គាត់លក់ប្រដាប់ប្រដាសិស្សានុសិស្ស សៀវភៅមេរៀនគ្រប់មុខ សៀវភៅប្រលោមលោក និងសៀវភៅធម៌ ។ យូរៗម្តង គាត់ក៏មានលក់សៀវភៅទស្សនាវដ្តីខ្លះដែរ ។ បន្តិចម្តងៗបណ្ណាគារក៏កាន់តែមានសៀវភៅច្រើនឡើងៗ ។ ចាប់តាំងពីគាត់បើកបណ្ណាគារមកខ្ញុំតែងមកជួយរៀបចំសៀវភៅតាមមុខសញ្ញា ដើម្បីអ្នកទិញស្រួលមើល និង ស្រួលយក ។ ខ្ញុំរៀបសៀវភៅតាមចំណងជើង តាមប្រធានបទ ឬ តាមអ្នកនិពន្ធជាដើម ។ ជាទូទៅ ខ្ញុំមកជួយគាត់នៅពេលដែលខ្ញុំទំនេរពីការសិក្សារបស់ខ្ញុំ ។ ក៏ប៉ុន្តែនៅពេល ដែលខ្ញុំមកជួយធ្វើការនោះ ខ្ញុំក៏ឆ្លៀតអានសៀវភៅទាំងនោះស្ទើរតែទាំងអស់ ទាំងសៀវភៅរៀន ទាំងសៀវភៅធម៌ ទាំងសៀវភៅប្រលោមលោក ដែលមានអ្នកនិពន្ធ ពីបុរាណ ឬ សម័យទំនើប ទាំងចាស់ទាំងក្មេង ។ ខ្ញុំអានសៀវភៅមិនរើសមុខ ទាំងសៀវភៅតុក្កតាកំប្លុកកំប្លែង សៀវភៅអប់រំសីលធម៌ សៀវភៅអប់រំផ្សេងៗទៀត រួមទាំងសៀវភៅអប់រំផ្លូវភេទ កីឡា ឬ សិល្បៈជាដើម។ល។ ដោយសារខ្ញុំមានការជក់ចិត្តជិតអារម្មណ៍ក្នុងការអានសៀវភៅនេះ យូរៗទៅ ខ្ញុំមិនសូវនៅផ្ទះប៉ុន្មានទេ ខ្ញុំចំណាយពេលវេលាយ៉ាងច្រើននៅក្នុងបណ្ណាគារនេះ ។ ខ្ញុំអានសៀវភៅភ្លេចបាយ ភ្លេចទឹក ដែលម្តងៗម្តាយខ្ញុំត្រូវស្រែកហៅខ្លាំងៗជាញឹកញាប់ ពីលើយ៉ខាងមុខផ្ទះ ឲ្យទៅទទួលទានអាហារទាន់ពេលវេលា ។ ដូច្នេះ ខ្ញុំមិនសូវបាននៅរួមទទួលទានអាហារជាមួយឪពុកម្តាយខ្ញុំ ដូចកូនៗឯទៀតឡើយ ។ ខ្ញុំទទួលស្គាល់ថាការអានសៀវភៅច្រើននេះ ក៏ជួយសំរួលឲ្យខ្ញុំមានចំណេះដឹងទូទៅច្រើន ធ្វើឲ្យការសិក្សារីកចំរើនឆាប់រហ័ស ពោលគឺរៀនឆាប់ចេះឆាប់ដឹងតទៅមុខទៀតដែរ ។

# ចង់ស្គាល់ភ្នំពេញខានបានលេខ១

កាលខ្ញុំនៅរៀននៅសាលាបឋមសិក្សាស្នាយពល ខ្ញុំតែងដើរទៅរៀន ។ ក៏ប៉ុន្តែនៅពេលដែលខ្ញុំប្រឡងជាប់ចូលរៀននៅអនុវិទ្យាល័យពារាំង ខ្ញុំមិនអាចដើរបានទៀតឡើយ ព្រោះសាលាអនុវិទ្យាល័យនៅឆ្ងាយពីផ្ទះ ។ ដូច្នេះ ឪពុកម្តាយខ្ញុំក៏ទិញកង់ឲ្យមួយ ។ ក្នុងឋានៈជាសិស្សអនុវិទ្យាល័យ ការរៀនសូត្ររបស់យើងក៏ត្រូវផ្លាស់ប្តូរដែរ ។ ជាដំបូងគេលែងហៅលោកគ្រូ ថាលោកគ្រូទៀតហើយ គេហៅថាសាស្ត្រាចារ្យ ។ យើងមិនមែនមានគ្រូតែម្នាក់ដូចពីមុនទេ យើងមានគ្រូច្រើនទៅតាមមុខវិជ្ជា ។ គ្រូម្នាក់បង្រៀនមុខវិជ្ជាមួយដាច់ដោយឡែកៗពីគ្នា ។ យើងឈប់ស្លៀកខោខ្លីអាវដៃខ្លីទៀតហើយ ។ ឥឡូវយើងស្លៀកខោគគីជើងវែង និង ពាក់អាវស ។ នៅអនុវិទ្យាល័យ មុខវិជ្ជាទាំងឡាយសុទ្ធតែជាភាសាបារាំង លើកលែងតែមុខវិជ្ជាអក្សរសាស្ត្រខ្មែរចេញ ។ នៅឆ្នាំទីមួយនៅអនុវិទ្យាល័យពារាំង ខ្ញុំរៀនបានលេខល្អខាងប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ គណិតសាស្ត្រ តែងសេចក្តី ទាំងខ្មែរទាំងបារាំង ។

តាមធម្មតាខ្ញុំត្រូវបានលេខ ១ ក៏ប៉ុន្តែខ្ញុំត្រូវធ្លាក់មកនៅលេខ ៣ វិញ ដោយសារខ្ញុំខានមិនបានចូលរួមប្រឡងក្នុងវិជ្ជាមួយមុខ នាធមាសទីមួយ ។ កាលនោះ ទីក្រុងភ្នំពេញជាទីក្រុងដ៏ល្អប្រណិតនៅអាស៊ីភាគអាគ្នេយ៍យើងនេះ ។ ទីក្រុងភ្នំពេញមានផ្លូវចរាចរខ្វាត់ខ្វែង មានហាងលក់ទំនិញដេរដាស មានសួនច្បារល្អប្រិមប្រិយ មានអាគារតូចធំ ខ្ពស់ទាប ទាំងផ្នែកសាធារណៈ ទាំងផ្នែកឯកជន ប្រកបដោយការតុបតែងរចនាដែលគួរឲ្យទាក់ទាញអារម្មណ៍ ។ ជាច្រើនដង ខ្ញុំចេះ តែចង់មកលេងភ្នំពេញ ។ នៅពេលណាបងប្រុសខ្ញុំ ដែលបានទៅរៀននៅរាជធានី មកលេងផ្ទះម្តងៗ គាត់តែងបបួលទៅលេងភ្នំពេញ ខ្ញុំចេះតែចង់ទៅជាមួយ ។ ក៏ប៉ុន្តែ រាល់ៗដងឪពុកម្តាយខ្ញុំមិនដែលអនុញ្ញាតឲ្យទៅលេងទេ ព្រោះខ្លាចខានរៀន ។ ចំពោះខ្ញុំ

ការទៅទស្សនាទីក្រុងភ្នំពេញ អាចចាត់ទុកជាការទទួលរង្វាន់ដ៏ធំអស្ចារ្យដែរ ។ តាមធម្មតា យើងអាចទៅលេងភ្នំពេញបាន ក្នុងឱកាសពិធីបុណ្យធំៗដូចជា បុណ្យអុំទូក បុណ្យឯករាជ្យជាតិ ជាពិសេស ក្នុងឱកាសសមាជជាតិ (កាលសម័យសង្គមរាស្ត្រនិយម រាជរដ្ឋាភិបាលរៀបចំជាសមាជជាតិមួយឆ្នាំពីរដង ដើម្បីឲ្យរាស្ត្របានសួរដេញដោលរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ចំពោះបញ្ហាទាំងឡាយដែលគេចង់ដឹងចង់យល់)។

ថ្ងៃមួយ នៅពេលដែលបងប្រុសទី២របស់ខ្ញុំគឺ បងស៊ីនឿន មកលេងផ្ទះ គាត់បបួលខ្ញុំទៅលេងភ្នំពេញ ។ ឮថា ទៅលេងភ្នំពេញ ខ្ញុំមានអារម្មណ៍ស្រើបស្រាលចង់ទៅលេងខ្លាំងណាស់ ហើយក៏ប្រឹងរកនឹកហេតុផលដើម្បីពន្យល់ឪពុកម្ដាយខ្ញុំឲ្យគាត់យល់ព្រម ។ កាលនោះ ខ្ញុំលាក់មិនឲ្យគាត់ដឹងថាខ្ញុំកំពុងប្រឡងឆមាសទេ ។ ដោយសារតែអវត្តមានក្នុងមុខវិជ្ជាមួយយ៉ាងដូចនេះ ទើបខ្ញុំត្រូវទទួលពិន្ទុសូន្យក្នុងមុខវិជ្ជានោះ ។ តាមធម្មតាសិស្សនៅអនុវិទ្យាល័យត្រូវទទួលពិន្ទុក្នុងមុខវិជ្ជាមួយពី ០ ទៅ ២០ ។

ជារៀងរាល់ឆ្នាំ ទីចាត់ការអនុវិទ្យាល័យតែងរៀបចំពិធីប្រគល់រង្វាន់ដល់ជ័យលាភីដែលបានពិន្ទុល្អប្រចាំត្រីមាស ឬ ប្រចាំឆមាស ឬ ប្រចាំឆ្នាំ ។ ក្នុងពិធីចែករង្វាន់លើកដំបូងនេះ ខ្ញុំគ្មានសង្ឃឹមថានឹងបានទទួលរង្វាន់អ្វី ដូចសិស្សឯទៀតទេ ដោយសារតែពិន្ទុសូន្យក្នុងមួយមុខវិជ្ជា ។ ដូច្នេះ ចំពោះពិធីចែករង្វាន់លើកនេះ ខ្ញុំហាក់ដូចជាមិនសូវយកចិត្តទុកដាក់ប៉ុន្មានឡើយ ។ ពេលមកដល់មាត់ទ្វារសាលា ខ្ញុំបណ្ដើរកង់យ៉ាងយឺតៗ សម្លឹងទៅខាងមុខឃើញកូនសិស្សឯទៀតជួបជុំគ្នាយ៉ាងកុះករនៅមុខទីចាត់ការរបស់អនុវិទ្យាល័យ ។ លោកនាយក កំពុងប្រកាសហៅឈ្មោះសិស្សដែលត្រូវទទួលរង្វាន់ ។ រង្វាន់មានពីរផ្នែកមួយគឺ ប័ណ្ណសរសើរចំពោះសិស្សដែលបានពិន្ទុច្រើន និង មួយទៀតគឺតារាងកិត្តិយស ។ សិស្សណាដែលត្រូវ

លោកនាយកប្រកាសហៅឈ្មោះ ក៏ស្ទុះលោតដោយអំណរ ហើយដើរទៅទទួលយ៉ាងសង្ហា ។ ក្រោយពីបានទទួលរង្វាន់ហើយ អ្នកខ្លះក៏ថយទៅកាន់ទីផ្សេង ។ នៅពេលដែលខ្ញុំដើរកាន់តែជិតទីកន្លែងចែករង្វាន់ ខ្ញុំសង្កេតឃើញ ក្រុមហ្វូងសិស្សានុសិស្សហាក់ដូចជាមានចំនួនចុះថយបន្តិច ។ លោកនាយកបានបញ្ចប់ការចែកប័ណ្ណសរសើរ ហើយកំពុងរៀបចំប្រកាសឈ្មោះជ័យលាភីដែលត្រូវទទួលតារាងកិត្តិយស ។

ខ្ញុំគ្មាននឹកសង្ឃឹមទាល់តែសោះថាអាចនឹងមានមុខទទួលរង្វាន់អ្វីមួយឡើយ ហើយកំពុងនឹករអ៊ូក្នុងចិត្តបន្ទោសខ្លួនឯងថាមិនគួរខានប្រឡង ហើយបែរជាទៅដើរលេង នៅភ្នំពេញទៅវិញយ៉ាងដូច្នេះសោះ ។ ខ្ញុំគួរតែទប់ចិត្តកុំឲ្យដឹកនាំខ្ញុំទៅដើរលេងចោលការប្រឡងយ៉ាងដូច្នេះ ។ កំពុងតែលង់ក្នុងក្តីមួហ្មងយ៉ាងនេះ ស្រាប់តែខ្ញុំឮសូរសម្លេងមួយមកដាស់អារម្មណ៍ខ្ញុំឲ្យភ្ញាក់ស្មារតីឡើង ។ ឈ្មោះខ្ញុំត្រូវលោកនាយកហៅមុនគេ ដើម្បីឲ្យទៅទទួលតារាងកិត្តិយស ។ នៅពេលភ្លាមៗនោះខ្ញុំមិនទាន់ជឿថាខ្ញុំអាចទទួលរង្វាន់នេះនៅឡើយទេ តែនៅពេលដែលឃើញអ្នកឯទៀតក្រឡេកមើលមកខ្ញុំគ្រប់គ្នា ទើបខ្ញុំប្រាកដក្នុងចិត្តថាខ្ញុំពិតជាជ័យលាភីមែន ។ ខ្ញុំមានសេចក្តីរីករាយក្នុងចិត្តឥតឧបមា ចំពោះហេតុការណ៍ដែលកើតឡើងសម្រាប់ខ្ញុំដែលខ្ញុំមិនបាននឹកដល់ទាល់តែសោះ ។ នេះជាសុភមង្គលមួយដែលខ្ញុំចងចាំរហូតអស់មួយជីវិត ។

# លាភូមិស្នាយពល

តាំងពីពេលដែលបងប្រុសខ្ញុំទាំងពីរនាក់ បានទៅរៀននៅទីក្រុងភ្នំពេញមក ការបញ្ជូនកូនឲ្យទៅបន្តវិជ្ជានៅរាជធានី បានក្លាយទៅជាប្រពៃណីមួយរបស់ឪពុក

ម្ដាយខ្ញុំ ។ ដូច្នេះ លើកនេះជាវេនរបស់ខ្ញុំគឺ ជាពេលដែលខ្ញុំត្រូវបែកចេញពីភូមិកំណើតរបស់ខ្ញុំ ដើម្បីទៅរៀនបន្តនៅភ្នំពេញ ។ បងប្រុសធំបង្អស់របស់ខ្ញុំគឺ បងឈឿន ឬ បងនាងមានភារកិច្ចស្វែងរកសាលា ។ កាលលើកមុនគាត់បានជួយឲ្យបងប្រុសបន្ទាប់គឺ បងស៊ីនឿន បានចូលរៀននៅវិទ្យាល័យព្រះយុគន្ធរ ។ ចំពោះខ្ញុំបងនាងរកបានសាលានៅទួលគោក ដែលមានឈ្មោះថា "វិទ្យាល័យសង្គមរាស្ត្រនិយម" ។ នៅឆ្នាំ ១៩៦៤ ខ្ញុំក៏មករស់នៅទីក្រុងភ្នំពេញ ។

ខ្ញុំឃ្លាតចេញពីភូមិកំណើតរបស់ខ្ញុំ កាលខ្ញុំអាយុបាន ១៤ ឆ្នាំ ហើយខ្ញុំមិនដែលនឹកគិតថា ថ្ងៃមួយគ្រួសារខ្ញុំទាំងមូលនឹងត្រូវបង្ខំចិត្តបែកចេញពីភូមិកំណើតនេះម្ដងណាឡើយ ។ ក្នុងរយៈពេលដែលខ្ញុំរស់នៅទីក្រុងភ្នំពេញ ខ្ញុំតែងតែឆ្លៀតទៅលេងភូមិកំណើតរបស់ខ្ញុំជារឿយៗ រហូតដល់ឆ្នាំ ១៩៧០ នៅពេលដែលប្រទេសកម្ពុជាយើងធ្លាក់ចូលក្នុងភ្នក់ភ្លើងសង្គ្រាម ។ តាំងពីពេលនោះមក ខ្ញុំត្រូវរង់ចាំអស់រយៈពេល ២២ ឆ្នាំ ទើបអាចវិលមកភូមិកំណើតខ្ញុំវិញ ។ ភូមិខ្ញុំ ក្នុងរយៈពេលដ៏វែងនេះ ក៏ដូចជាភូមិនានាឯទៀតនៅទូទាំងប្រទេសកម្ពុជាទាំងមូលដែរ ត្រូវទទួលរងទុក្ខដោយសារសង្គ្រាមបំផ្លិចបំផ្លាញ ដោយសារបដិវត្តន៍ប្រកបដោយអំពើសាហាវយង់ឃ្នងប្រល័យពូជសាសន៍ ដោយសារការបែកបាក់ព្រាត់ប្រាស់គ្នា ដោយសារការលុកលុយនៃកងទ័ពបរទេស និង ដោយសារអស្ថិរភាពនយោបាយ ។ អ្វីដែលកើតឡើង នៅភូមិកំណើតរបស់ខ្ញុំ ក៏អាចកើតមានឡើងនៅតាមភូមិនានាឯទៀតទូទាំងប្រទេស ដោយហេតុថាភូមិទាំងនោះមានលក្ខណៈវប្បធម៌ សង្គម និងសេដ្ឋកិច្ចប្រហាក់ប្រហែលគ្នា ។ ខ្ញុំតែងនឹកដល់ភូមិខ្ញុំជានិច្ច នៅពេលដែលខ្ញុំពិចារណាអំពីតម្លៃនៃអ្វីដែលហៅថា "សេរីភាព" "ប្រពៃណីជាតិ" "សេចក្ដីថ្លៃថ្នូររបស់មនុស្ស" និង "វឌ្ឍនភាព" ។